ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ
# ស្តីពី
# ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា
# ឆ្នាំ២០១៩-២០២៣

ថ្ងៃចន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

## អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំនាវាកម្ពុជា ឈានទៅរកការអភិវឌ្ឍគួរជាទីមោទនៈ ក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ ដោយបាននាំកម្ពុជាឈានមកដល់ដំណាក់កាលរីកចម្រើនថ្មី ទាំងក្នុងទិដ្ឋភាពនយោបាយ ការទូត សេដ្ឋកិច្ច និងសង្គម។ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលដ៏ធំធេងនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ទាំង៣ ដំណាក់កាលកន្លងមក **រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា** បានដាក់ចេញនូវ **កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដែលចំណុចទី៦ នៃមុំទី១ "ការអភិវឌ្ឍទីផ្សារការងារ" ក្នុងចតុកោណទី៣ "ការអភិវឌ្ឍវិស័យឯកជន និងការងារ" មានចែងអំពីការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់ លើកកម្ពស់ការការពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្តន៍ តាមរយៈការផ្តល់ប្រឹក្សារកការងារធ្វើ ការបង្កើតមុខរបរដោយខ្លួនឯង ការទទួលស្គាល់ជំនាញ និងការផ្ទេរបបសន្តិសុខសង្គមមកក្នុងប្រទេស។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកថាទេសន្តរប្រវេសន៍ការងារ ពិតជាបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ដោយបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋបានកាន់តែប្រសើរឡើង។ នៅក្នុងបរិបទនេះ ទេសន្តរប្រវេសន៍ការងារមិនត្រឹមតែបាននាំមកនូវអត្ថប្រយោជន៍សម្រាប់ពលករ និងគ្រួសារប៉ុណ្ណោះទេ ថែមទាំងបានផ្តល់នូវផលប្រយោជន៍ជាវិជ្ជមានដល់សហគមន៍ និងប្រទេសជាតិទាំងមូលផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាកំណត់ថា ការធ្វើទេសន្តរប្រវេសន៍ការងារទៅក្រៅប្រទេស គឺជាឱកាសការងារ និងជាជម្រើសបន្ថែមលើឱកាសការងារ និងជម្រើសការងារដែលមាននៅក្នុងស្រុកសម្រាប់ពលរដ្ឋកម្ពុជា ហើយការធ្វើទេសន្តរប្រវេសន៍ការងារនេះ គឺចេញពីឆន្ទៈផ្ទាល់របស់ពួកគេ ដោយមិនមានការចាប់បង្ខំណាមួយឡើយ។ ការដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ ជាផ្នែកមួយនៃការអនុវត្តរបៀបវារៈនៃកម្មវិធីនយោបាយរបស់ **រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា** ដែលបានដាក់ចេញ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដើម្បី កំណើនការងារ សមធម៌ និងប្រសិទ្ធភាព ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ ផងដែរ។

គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ សំដៅលើកកម្ពស់ប្រសិទ្ធភាព នៃការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ លើគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១០-២០១៤ និង ឆ្នាំ២០១៥-២០១៨ ដោយផ្តោតលើសសរស្តម្ភធំៗចំនួនបី៖ (១) ការពង្រឹងអភិបាលកិច្ចទេសន្តរ

ប្រវេសន៍ការងារ (២) ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និង (៣) ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។

គោលនយោបាយនេះ មានគោលដៅដាក់លាក់ផ្តោតលើការធ្វើទេសន្តរប្រវេសន៍ការងារ ប្រកបដោយសុវត្ថិភាព ទទួលបានផលប្រយោជន៍ខ្ពស់ជាអតិបរមាប្រកបដោយផលិតភាពខ្ពស់ និងប្រកបដោយបទពិសោធន៍ជាវិជ្ជមានសម្រាប់ពលករទេសន្តរប្រវេសន៍ទាំងអស់ដោយមិនគិតពីអាយុ ពិការភាព វប្បធម៌ ក្រុមជនជាតិភាគតិចអត្តសញ្ញាណ យេនឌ័រ ភេទ ជំនឿ សាសនា ទស្សនៈនយោបាយ ស្ថានភាពខាងផ្លូវច្បាប់ សមាជិកសហគមន៍ ឬសហជីព មុខរបរ និងការងាររបស់ពលករឡើយ។ ជាងនេះទៅទៀត គោលនយោបាយនេះបានផ្តោតលើការលុបបំបាត់ឧបសគ្គខាងផ្នែកហិរញ្ញវត្ថុ និងកត្តារាំងផ្សេងៗទៀត ដែលអាចធ្វើឱ្យពលករទេសន្តរប្រវេសន៍ជាស្ត្រី បុរស និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះផ្សេងទៀត អាចទទួលបានឱកាសការងារសមរម្យ។ គោលនយោបាយនេះក៏បានដាក់ចេញផងដែរនូវវិធានការនានា ដោយផ្តោតលើការទទួលស្គាល់ជំនាញ ការទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម ការផ្តល់សេវាគាំទ្រនានា ដែលពលករទេសន្តរប្រវេសន៍ត្រូវទទួលបាន និងរួមចំណែកកាត់បន្ថយតម្លៃនៃការធ្វើទេសន្តរប្រវេសន៍ការងារ ដែលជាបន្ទុកមួយផ្នែករបស់ពលករឱ្យបានសមរម្យ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អ្នកផ្តល់សេវា អង្គការសង្គមស៊ីវិល វិស័យឯកជន សហជីព និងប្រទេសទទួល ដើម្បីប្រើប្រាស់ និងអនុវត្តគោលនយោបាយនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ឯកសារគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នេះ គឺជាលទ្ធផលនៃកិច្ចពិគ្រោះយោបល់ត្រីភាគីបូក ដែលបានរៀបចំឡើងជាច្រើនលើករវាងភាគីពាក់ព័ន្ធដែលរួមមានក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា សមាគមនិយោជក សហជីពកម្មករនិយោជិត សមាគមទីភ្នាក់ងារជ្រើសរើសឯកជន អង្គការជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដោយបានឆ្លុះបញ្ចាំងទៅលើចំណុចអាទិភាព ដែលបានលើកឡើងនៅក្នុងក្របខណ្ឌឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍ ក៏ដូចជាកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៥-២០៣០ របស់អង្គការសហប្រជាជាតិ ដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងវិស័យជាអាទិភាពនៅកម្រិតតំបន់ និងពិភពលោក។

ខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់ភាគីទាំងអស់ ដែលបានចូលរួមអភិវឌ្ឍគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ នេះឡើង ជាពិសេសអង្គការអន្តរជាតិខាងការងារ (ILO) ដែលបានផ្តល់ធាតុចូលជាបច្ចេកទេសដ៏មានសារៈសំខាន់ និងជំនួយហិរញ្ញវត្ថុដែលផ្តល់ឱ្យដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម នៃរដ្ឋាភិបាលអូស្ត្រាលី។

ថ្ងៃចន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការនៃការរៀបចំគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣។

គោលនយោបាយនេះ ត្រូវបានរៀបចំឡើងដោយការពិភាក្សាពិគ្រោះយោបល់ ដែលមានការចូលរួមពីដៃគូត្រីភាគីបូក ដូចជាក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទីភ្នាក់ងារជាតិមុខរបរ និងការងារ សមាគមនិយោជក សហជីពកម្មករនិយោជិត សមាគមទីភ្នាក់ងារជ្រើសរើសឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណចំពោះកម្មវិធីសកម្មភាពត្រីភាគី ដើម្បីធ្វើឱ្យប្រសើរឡើងនូវទេសន្តរប្រវេសន៍ការងារ និងរួមចំណែកដល់ការរីកចម្រើន និងការអភិវឌ្ឍក្នុងតំបន់អាស៊ាន (កម្មវិធីត្រីកោណក្នុងតំបន់អាស៊ាន) នៃអង្គការ ILO ដែលបានផ្តល់ជំនួយបច្ចេកទេសដ៏មានសារៈសំខាន់ក្នុងការរៀបចំគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងជំនួយហិរញ្ញវត្ថុ ដែលផ្តល់ឱ្យដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈ ក្រសួងការបរទេស និងពាណិជ្ជកម្ម នៃរដ្ឋាភិបាលអូស្ត្រាលី។

# អក្សរបំព្រួញ

| អក្សរកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ACRA | Association of Cambodian Recruitment Agencies | សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEC | ASEAN Economic Community | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| AFML | ASEAN Forum on Migrant Labour | វេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ |
| AMS | ASEAN Member States | រដ្ឋសមាជិកអាស៊ាន |
| AQRF | ASEAN Qualifications Reference Framework | ក្របខណ្ឌគុណវុឌ្ឍិអាស៊ាន |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CAMFEBA | Cambodian Federation of Employers and Business Association | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ |
| CQF | Cambodia Qualifications Framework | ក្របខណ្ឌគុណវុឌ្ឍិកម្ពុជា |
| DFAT | Department of Foreign Affairs and Trade (Australia) | ក្រសួងការបរទេស និងពាណិជ្ជកម្ម (ប្រទេសអូស្ត្រាលី) |
| EPS | Employment Permit System - Republic of Korea | ប្រព័ន្ធអនុញ្ញាតមុខរបរ - សាធារណរដ្ឋកូរ៉េ |
| ILO | International Labour Organization | អង្គការអន្តរជាតិខាងការងារ |
| IOM | International Organization for Migration | អង្គការអន្តរជាតិខាងទេសន្តរប្រវេសន៍ |
| LGBT+ | Lesbian, Gay, Bisexual, Transgender, and others | អ្នកស្រឡាញ់ភេទដូចគ្នា |
| LMP | Labour Migration Policy | គោលនយោបាយស្តីពីទេសន្តរ |

| | | |
|---|---|---|
| | | ប្រវេសន៍ការងារ |
| M&E | Monitoring and Evaluation | ការត្រួតពិនិត្យនិងវាយតម្លៃ |
| MAC | Manpower Association of Cambodia | សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា |
| MOAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MOEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MOC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MOEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MOFA&IC | Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| MOI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MOIN | Ministry of Information | ក្រសួងព័ត៌មាន |
| MOJ | Ministry of Justice | ក្រសួងយុត្តិធម៌ |
| MOLVT | Ministry of Labour and Vocational Training | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOP | Ministry of Planning | ក្រសួងផែនការ |
| MOSAVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MTOSB | Manpower Training and Overseas Sending Board | គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស |
| MOU | Memorandum of Understanding | អនុស្សរណៈនៃការយោគយល់គ្នា |
| MRC | Migrant Worker Resource Centre | មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ |
| MRS | Mutual Recognition of Skills | ការទទួលស្គាល់ជំនាញទៅវិញទៅមក |
| MWF | Migrant Welfare Fund | មូលនិធិសុខមាលភាពពលករទេសន្តរប្រវេសន៍ |

| | | |
|---|---|---|
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NEA | National Employment Agency | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NESB | National Economic and Social Development Board (Thailand) | ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (ប្រទេសថៃ) |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NSSF | National Social Security Fund | បេឡាជាតិរបបសន្តិសុខសង្គម |
| NTB | National Training Board | គណៈកម្មាធិការជាតិបណ្តុះបណ្តាល |
| ODA | Official Development Assistance | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| PDOLVT | Provincial Department of Labour and Vocational Training | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| PRA | Private Recruitment Agency | ទីភ្នាក់ងារជ្រើសរើសឯកជន |
| SSS | Social Security Scheme | របបសន្តិសុខសង្គម |
| TVET | Technical and Vocational Education and Training | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ |
| TU | Trade Union | សហជីព |
| UNDAF | United Nations Development Assistance Framework | ក្របខណ្ឌជំនួយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |

# មាតិកា


អារម្ភកថា ........ I
សេចក្តីថ្លែងអំណរគុណ ........ III
អក្សរបំព្រួញ ........ V
មាតិកា ........ ១
១- សេចក្តីផ្តើម ........ ១
២- និន្នាការទេសន្តរប្រវេសន៍ការងារ ........ ៣
២.១- កត្តាកំណត់និន្នាការទេសន្តរប្រវេសន៍ការងារ ........ ៣
ក. ប្រជាសាស្ត្រកម្ពុជា ........ ៣
ខ. សេដ្ឋកិច្ច និងទីផ្សារការងារកម្ពុជា ........ ៥
គ. ស្ថានភាពតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងតំបន់ ........ ៦
ឃ. ស្ថានភាពប្រាក់ឈ្នួល ........ ៧
២.២- និន្នាការនៃទេសន្តរប្រវេសន៍ការងារកម្ពុជា ........ ៩
៣- ក្របខណ្ឌទេសន្តរប្រវេសន៍ការងារ ........ ១០
៣.១- ក្របខណ្ឌគោលនយោបាយ ........ ១១
៣.២- ក្របខណ្ឌគតិយុត្តជាតិ ........ ១១
៣.៣- លិខិតូបករណ៍អន្តរជាតិ ........ ១២
៣.៤- លិខិតូបករណ៍ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់-ទ្វេភាគី ........ ១៣
៣.៥- ក្របខណ្ឌស្ថាប័ន ........ ១៤
៤- បញ្ហាប្រឈម ........ ១៥
៥- ចក្ខុវិស័យ ........ ១៥
៦- គោលបំណង និងគោលដៅ ........ ១៦
៦.១- គោលបំណង ........ ១៦
៦.២- គោលដៅ ........ ១៦
៧- យុទ្ធសាស្ត្រ ........ ១៧
៧.១- គោលបំណងទី១៖ ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ ........ ១៧
៧.២- គោលបំណងទី២៖ ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ........ ២១
៧.៣- គោលបំណងទី៣៖ ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ២៤
៨- ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងប្រភពហិរញ្ញវត្ថុ ........ ២៦
៩- សេចក្តីសន្និដ្ឋាន ........ ២៦
ឧបសម្ព័ន្ធ១ ៖ គំនូសបំព្រួញក្របខ័ណ្ឌនៃគោលនយោបាយ ........ ២៧
ឧបសម្ព័ន្ធ២ ៖ តារាងម៉ាទ្រីកនៃគោលនយោបាយ គោលបំណង គោលដៅ និងផែនការសកម្មភាព ........ ២៩
ឧបសម្ព័ន្ធ៣ ៖ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងទ្វេភាគី ........ ៤៧
ឧបសម្ព័ន្ធ៤ ៖ តួនាទី និងភារកិច្ចរបស់អនុព័ន្ធការងារ ........ ៤៩

# គោលនយោបាយ
# ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣

## ១- សេចក្តីផ្តើម

ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជារក្សាបានពេញលេញនូវសន្តិភាព ការឯកភាពជាតិ ស្ថិរភាពនយោបាយ ដែលធ្វើឱ្យកម្ពុជាកំពុងបន្តទទួលបាននូវការរីកចម្រើនលើគ្រប់វិស័យ និងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧,៧%។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងឆាប់រហ័សនេះបានជួយកាត់បន្ថយអត្រាភាពក្រីក្រ បង្កើតការងារប្រកបដោយគុណភាពកាន់តែច្រើន និងជំរុញការអភិវឌ្ឍនៃវិស័យឯកជន។ ជាក់ស្តែង កំណើនដ៏ខ្ពស់នេះបានធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់មនុស្សម្នាក់នៅកម្ពុជាបានកើនឡើងទ្វេដងក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ឬជិត ៦ដង ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ហើយបានរុញកម្ពុជាឱ្យងើបចេញផុតពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥។

សមិទ្ធផលគួរជាទីមោទនៈទាំងនេះ អាចសម្រេចទៅបាន ក្រោមនយោបាយ**ឈ្នះ-ឈ្នះ** ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចបង្វែរធនធានដែលជាផលលាភពីសន្តិភាព មកធ្វើការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់លើការកសាងហេដ្ឋារចនាសម្ព័ន្ធ (ទឹក ផ្លូវ ភ្លើង) ព្រមទាំងការអភិវឌ្ឍមូលធនមនុស្ស ដែលបានបង្កើតជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការចាប់ផ្តើមហក់ឡើងនៃសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះ ការដាក់ចេញជាបន្តបន្ទាប់នូវគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាល ដែលផ្តោតអាទិភាពលើការបើកចំហសេដ្ឋកិច្ច និងធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងតំបន់ និងសកលលោក បានបង្កលក្ខណៈអំណោយផលដល់លំហូរពាណិជ្ជកម្ម និងទុនវិនិយោគពីបរទេស ដែលបានជំរុញសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេស ជាពិសេសវិស័យដែលប្រើប្រាស់កម្លាំងពលកម្មខ្លាំង ព្រមទាំងការធ្វើពិពិធកម្មពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម និងសេវាកម្ម។ វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនេះ បានផ្តល់លទ្ធភាពក្នុងការបង្កើតការងារមានគុណភាពកាន់តែច្រើន ការដំឡើងប្រាក់ឈ្នួល ការលើកកម្ពស់កម្រិតជីវភាព ការពង្រីកកិច្ចគាំពារសង្គមកាន់តែទូលំទូលាយ និងការកាត់បន្ថយការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយប្រថុយប្រថានពីមួយឆ្នាំទៅមួយឆ្នាំ។ ជាលទ្ធផល ចន្លោះឆ្នាំ២០១៣ ទៅឆ្នាំ២០១៨ ក្នុងចំណោមការងារថ្មីបន្ថែមចំនួន ១,៣លានកន្លែង ដែលត្រូវបានបង្កើត មានការកើនឡើង ៨៩៤ ពាន់នាក់ ស្ថិតនៅក្នុងវិស័យឧស្សាហកម្ម, ១ ០០៥ពាន់នាក់ នៅក្នុងវិស័យសេវាកម្ម, និងចំណែកការងារនៅក្នុងវិស័យកសិកម្ម ដែលមានផលិតភាពទាបជាងគេ មានការថយចុះចំនួន ៦១៧ពាន់នាក់។ ស្របជាមួយនឹងការបង្កើតការងារក្នុងស្រុក រាជរដ្ឋាភិបាលក៏បានស្វះស្វែងជួយរកការងារក្រៅប្រទេសបន្ថែម សម្រាប់ប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងការទទួលបានមកវិញនូវកម្លាំងពលកម្មជំនាញសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ គិតត្រឹមឆ្នាំ២០១៨ ពលករកម្ពុជាដែលកំពុងធ្វើការ និងស្នាក់នៅបរទេសមានចំនួន ១,២៣លាននាក់។ បើយោងតាមការប៉ាន់ស្មានរបស់ធនាគារពិភពលោក ប្រាក់បញ្ញើរបស់ពលករកម្ពុជានៅបរទេសត្រឡប់មកចូលក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ២០១៨ គឺប្រមាណ ១,៤៣ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ៥,៨%នៃ ផ.ស.ស ដែលកើនឡើងប្រមាណ ៤២,៩% ពី ១ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៣។

ទេសន្តរប្រវេសន៍ការងារ គឺជាកម្លាំងជំរុញដ៏សំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមក្នុងប្រទេសកម្ពុជា ដោយមិនត្រឹមតែបានផ្តល់ឱកាសដល់ប្រជាពលរដ្ឋកម្ពុជា អាចរកប្រាក់ចំណូលបានសមរម្យ និងមានលទ្ធភាពផ្ញើប្រាក់មកសមាជិកគ្រួសាររបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តល់នូវចំណេះដឹងថ្មីៗ បទពិសោធន៍ការងារ និងជំនាញបច្ចេកទេស ដែលជាមូលដ្ឋានដ៏មានសារៈសំខាន់សម្រាប់ឱ្យពួកគេអាចយកទៅប្រើប្រាស់សម្រាប់ថ្ងៃអនាគត។

ទោះបីជាកន្លងមក កម្ពុជាសម្រេចបានកំណើនខ្ពស់ក្នុងរយៈពេលដ៏វែង និងកំពុងបន្តស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចល្អនាពេលបច្ចុប្បន្ន ក៏ប៉ុន្តែដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គមជាតិយើងបានឈានចូលមកដល់ដំណាក់កាលដែលត្រូវប្រឈមនឹងបញ្ហាថ្មីទៀត ដែលមានសភាពខុសគ្នាយ៉ាងខ្លាំងពីអតីតកាល ដែលយើងត្រូវខិតខំដំនះដោះស្រាយដើម្បីអាចរក្សាបានកំណើនខ្ពស់ បង្កើតការងារនិងមុខរបរកាន់តែប្រសើរស្របតាមក្តីប្រាថ្នាកាន់តែខ្ពស់ឡើងរបស់ប្រជាពលរដ្ឋ និងការទាញយកផលវិជ្ជមានជាអតិបរមាពីទេសន្តរប្រវេសន៍ការងារ។ ឆ្លើយតបទៅនឹងបម្រែបម្រួលនៃបរិការណ៍នេះ **រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា** បានដាក់ចេញ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ក៏ដូចជា **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ដែលរួមបញ្ចូលគ្នានូវដំណោះស្រាយគ្រប់ជ្រុងជ្រោយ សំដៅជំរុញការកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិពីការពឹងផ្អែកលើកំណើនជំរុញដោយកត្តាផលិតកម្ម ទៅពឹងផ្អែកលើផលិតភាព និងការបង្កើតតម្លៃបន្ថែម សំដៅពង្រឹងភាពប្រកួតប្រជែង បន្តធានាបានកំណើនខ្ពស់ បង្កើតការងារកាន់តែប្រសើរទាំងក្នុងនិងក្រៅប្រទេស និងបង្កើនប្រាក់ចំណូលប្រកបដោយស្ថិរភាព និងបរិយាប័ន្ន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ និងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ សំដៅបង្កើនឱកាសការងារសមរម្យជូនប្រជាពលរដ្ឋ និងលើកកម្ពស់ផលិតភាពការងារ ជំរុញការអភិវឌ្ឍជំនាញនិងធនធានមនុស្ស ព្រមទាំងពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងប្រជាសាស្ត្រទាំងក្នុងតំបន់ និងសកលលោក។

បន្ថែមពីលើគោលនយោបាយខាងលើ រាជរដ្ឋាភិបាល នឹងដាក់ចេញ **"គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣"** សំដៅពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ បង្កើនប្រសិទ្ធភាពក្នុងការការពារ ការលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍ និងការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ គោលនយោបាយនេះ គឺជាឯកសារគោលនយោបាយដំណាក់កាលទី៣ ដែលរាជរដ្ឋាភិបាលដាក់ចេញ ដោយបានធ្វើការប្រមូលផ្តុំធាតុចូលពីសំណាក់ដៃគូក្នុងសង្គម និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសបទពិសោធន៍ និងការអនុវត្តល្អៗ ដែលអនុវត្តបានជោគជ័យនាពេលកន្លងមកក្នុងដំណាក់កាលទី១ នៅឆ្នាំ២០១០ និងដំណាក់កាលទី២ នៅឆ្នាំ២០១៤ ព្រមទាំងធ្វើអាទិភាពនីយកម្មនៃសកម្មភាពការងារ ដោយកំណត់នូវស្ថាប័នដឹកនាំ និងស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តវិធានការ ព្រមទាំងបង្កើតជាក្របខណ្ឌគ្រប់គ្រងទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ប្រសិទ្ធភាព និងឈរលើមូលដ្ឋានសិទ្ធិ និងវិសាលភាពយេនឌ័រ។

# ២- និន្នាការទេសន្តរប្រវេសន៍ការងារ

## ២.១- កត្តាកំណត់និន្នាការទេសន្តរប្រវេសន៍ការងារ

### ក. ប្រជាសាស្ត្រកម្ពុជា

បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពអន្តរកម្មប្រជាសាស្ត្រ (Demographic Transition) ដែលផ្លាស់ប្តូរពីអត្រាបង្កកំណើត និងអត្រាមរណៈខ្ពស់ទៅអត្រាបង្កកំណើត និងអត្រាមរណៈទាបវិញ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៨ ប្រជាជនស្ថិតក្រោមអាយុ ២៤ឆ្នាំ មានចំនួនច្រើនជាងគេនៅក្នុងរចនាសម្ព័ន្ធប្រជាសាស្ត្រ ប្រមាណ ៥០,២% នៃប្រជាជនសរុបដែលក្រុមអាយុនេះ គឺតំណាងឱ្យអ្នកដែលបានកើតក្នុងអំឡុងឆ្នាំ១៩៩០។ ជាមួយនឹងរចនាសម្ព័ន្ធបែបនេះ កម្ពុជាមានប្រជាជនវ័យក្មេងចំនួនច្រើនសម្រាប់ផ្គត់ផ្គង់នៅក្នុងសេដ្ឋកិច្ច ហើយក្រុមប្រជាជនវ័យក្មេងទាំងនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជាពិសេសបន្តចូលរួមជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលប្រមាណជាបីទសវត្សរ៍ខាងមុខ។ ទន្ទឹមនឹងនេះ តារាងទី១ ក៏បានបង្ហាញថាបរិមាណភាគនៃប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ (អាយុ១៥ ទៅ៦៤ឆ្នាំ) បានកើនឡើងពី ៥២,៨% នៅឆ្នាំ១៩៩០ ទៅ ៦៤,២% នៅឆ្នាំ២០១៨ និងប្រសិនគិតជាចំនួនវិញ គឺមានការកើនឡើងទ្វេដងពី ៤,៧លាន ទៅ១០,៤ លាននាក់ក្នុងរយៈពេលដូចគ្នានេះ ហើយនៅឆ្នាំ២០២៥ ចំនួននេះនឹងបន្តកើនឡើងដល់ ១១,៦លាននាក់ ឬស្មើនឹង ៦៥,១% នៃប្រជាជនសរុប។

**តារាងទី ១ ៖ ចំនួន និងបរិមាណភាគប្រជាជនកម្ពុជា តាមអាយុ ពីឆ្នាំ១៩៩០ ដល់ ២០២៥**

| ចំនួនប្រជាជន (ពាន់នាក់) | 1990 | 2000 | 2010 | 2018 | 2025 |
|---|---|---|---|---|---|
| 0-14 | 3,974 | 5,054 | 4,769 | 5,071 | 5,222 |
| 15-24 | 1,695 | 2,398 | 2,988 | 3,079 | 3,039 |
| 25-34 | 1,233 | 1,746 | 2,401 | 2,886 | 3,043 |
| 35-44 | 861 | 1,256 | 1,640 | 1,911 | 2,823 |
| 45-54 | 562 | 825 | 1,225 | 1,540 | 1,384 |
| 55-64 | 388 | 499 | 751 | 1,016 | 1,312 |
| 65+ | 260 | 374 | 534 | 742 | 987 |
| **15-64** | **4,739** | **6,724** | **9,006** | **10,433** | **11,600** |
| បរិមាណភាគ (%) នៃប្រជាជនសរុប | | | | | |
| 0-14 | 44.3% | 41.6% | 33.3% | 31.2% | 29.3% |
| 15-24 | 18.9% | 19.7% | 20.9% | 19.0% | 17.1% |
| 25-34 | 13.7% | 14.4% | 16.8% | 17.8% | 17.1% |
| 35-44 | 9.6% | 10.3% | 11.5% | 11.8% | 15.9% |
| 45-54 | 6.3% | 6.8% | 8.6% | 9.5% | 7.8% |
| 55-64 | 4.3% | 4.1% | 5.3% | 6.3% | 7.4% |
| 65+ | 2.9% | 3.1% | 3.7% | 4.6% | 5.5% |
| **15-64** | **52.8%** | **55.3%** | **62.9%** | **64.2%** | **65.1%** |

*ប្រភព៖ ធ្វើការប៉ាន់ស្មានពីទិន្នន័យ United Nations Population Division*

ប្រសិនបើធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសជិតខាង និងតំបន់ បរិមាណភាគនៃប្រជាជនកម្ពុជាស្ថិតនៅក្នុងវ័យធ្វើការ ទាបជាងប្រទេសថៃ និងប្រទេសវៀតណាម។ ជាមួយនឹងប្រជាជនវ័យក្មេង និងអត្រាបង្កកំណើតខ្ពស់ កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃផលលាភប្រជាសាស្ត្រ ដោយបរិមាណភាគនៃប្រជាជនស្ថិតនៅក្នុងវ័យធ្វើការ ត្រូវបានព្យាករណ៍ថានឹងបន្តកើនឡើងរហូតដល់ ឆ្នាំ២០៤៥។ ទន្ទឹមនឹងនេះ សិង្ហបុរី ម៉ាឡេស៊ី ថៃ និងវៀតណាម បានឆ្លងកាត់ដំណាក់កាលកំពូលរបស់ខ្លួនរួចហើយ ហើយបរិមាណភាគនៃប្រជាជនស្ថិតនៅក្នុងវ័យធ្វើការបានចាប់ផ្តើមធ្លាក់ចុះជាបណ្តើរៗ ដោយនិន្នាការនេះបានចាប់ផ្តើមនៅប្រទេសថៃ និងប្រទេសសិង្ហបុរីតាំងពី ឆ្នាំ២០១០ នៅប្រទេសវៀតណាមចាប់ពី ឆ្នាំ២០១៣ និងនៅប្រទេសម៉ាឡេស៊ីចាប់ពីឆ្នាំ២០១៨ (រូបទី១ ខាងក្រោម)។ និន្នាការនេះត្រូវបានសង្កេតឃើញរួចហើយនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ដូចជាប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ។ ដោយសារកត្តាប្រជាសាស្ត្រនេះ ប្រទេសមួយចំនួននៅក្នុងតំបន់បាននឹងកំពុងប្រឈមខ្វះខាតកម្លាំងពលកម្ម ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។

**រូបទី១៖ បរិមាណភាគអ្នកស្ថិតនៅក្នុងវ័យធ្វើការកម្ពុជាធៀបនឹងបណ្តាប្រទេសផ្សេងៗ ពីឆ្នាំ១៩៩០-២០៦០**




*ប្រភព៖ ធ្វើការប៉ាន់ស្មានពីទិន្នន័យ United Nations Population Division*

បើទោះបីជាការអប់រំរបស់ប្រជាជនស្ថិតក្នុងវ័យធ្វើការ បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយចំនួនអ្នកដែលទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងមធ្យមសិក្សាទុតិយភូមិបានកើនឡើងទ្វេដង នៅក្នុងចន្លោះ ឆ្នាំ២០១៣ និងឆ្នាំ២០១៧ ក៏ភាគច្រើននៃប្រជាជនស្ថិតក្នុងវ័យធ្វើការគឺនៅមានកម្រិតអប់រំ និងកម្រិតជំនាញទាប។ ក្នុងបរិការណ៍នេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការអភិវឌ្ឍជំនាញ ជាកត្តារួមចំណែកដ៏សំខាន់ក្នុងការបង្កើនឱកាសសម្រាប់កម្លាំងពលកម្មកម្ពុជា ក្នុងការចាប់យកការងារល្អប្រសើរទាំងក្នុង និងក្រៅប្រទេស។ ទន្ទឹមនឹងនេះ ក្នុងបរិបទទេសន្តរប្រវេសន៍ការងារ ការទទួលស្គាល់ជំនាញនឹងដើរតួយ៉ាងសំខាន់ក្នុងការផ្តល់លទ្ធភាពឱ្យពលករប្រើប្រាស់ជំនាញ ចំណេះដឹង និងធនធាន ដែលពួកគេទទួលបានពីការធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គម ប្រកបដោយប្រសិទ្ធភាព។

## តារាងទី២៖ កម្រិតអប់រំរបស់ប្រជាជនស្ថិតក្នុងវ័យធ្វើការ (១៥-៦៤ឆ្នាំ) ឆ្នាំ២០១៣ និងឆ្នាំ២០១៧

| កម្រិតអប់រំ | ចំនួន (ពាន់នាក់) | | | | | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2017) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | | | 2017 | | | ចំនួន(ពាន់នាក់) | | | បរិមាណភាគ (%) | | | អត្រាកំណើន (%) | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ឧត្តមសិក្សា | 214 | 112 | 326 | 394 | 271 | 665 | 45 | 40 | 85 | 39.4 | 44.7 | 41.7 | 16.5 | 24.6 | 19.5 |
| មធ្យមសិក្សាទុតិយភូមិ | 285 | 181 | 466 | 471 | 363 | 834 | 46 | 46 | 92 | 40.7 | 51.4 | 45.3 | 13.4 | 19.0 | 15.7 |
| មធ្យមសិក្សាបឋមភូមិ | 1,030 | 749 | 1,779 | 976 | 884 | 1,860 | -13 | 34 | 20 | -11.7 | 38.1 | 10.0 | -1.3 | 4.2 | 1.1 |
| បឋមសិក្សា | 1,266 | 1,294 | 2,561 | 1,390 | 1,318 | 2,708 | 31 | 6 | 37 | 27.1 | 6.6 | 18.1 | 2.4 | 0.5 | 1.4 |
| មិនបញ្ចប់ថ្នាក់បឋមសិក្សា | 1,402 | 1,814 | 3,216 | 1,375 | 1,757 | 3,131 | -7 | -14 | -21 | -6.0 | -16.1 | -10.4 | -0.5 | -0.8 | -0.7 |
| គ្មាន ឬរៀនបានតិចតួច | 402 | 856 | 1,257 | 450 | 768 | 1,218 | 12 | -22 | -10 | 10.5 | -24.7 | -4.9 | 2.9 | -2.7 | -0.8 |
| សរុប | 4,599 | 5,006 | 9,604 | 5,056 | 5,360 | 10,416 | 114 | 89 | 203 | 100.0 | 100.0 | 100.0 | 2.4 | 1.7 | 2.0 |

*ប្រភព៖ អង្កេតសង្គមសេដ្ឋកិច្ចឆ្នាំ២០១៣ និងឆ្នាំ២០១៧*

### ខ. សេដ្ឋកិច្ច និងទីផ្សារការងារកម្ពុជា

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណជា ៧,០% នៅក្នុងចន្លោះឆ្នាំ២០១៣ ទៅឆ្នាំ២០១៨ ទោះបីស្ថានភាពសេដ្ឋកិច្ចសកលលោក មានលក្ខណៈមិនប្រាកដប្រជា ហើយប្រទេសមួយចំនួនកំពុងជួបប្រទះវិបត្តិបំណុលសាធារណៈ។ ក្នុងរយៈពេលដូចគ្នានេះ ចំនួនអ្នកមានការងារធ្វើ (១៥ឆ្នាំ+) បានកើនឡើងចំនួន ១,៣លាននាក់ ពី ៨,៣លាននាក់ នៅឆ្នាំ២០១៣ ទៅ៩,៦លាននាក់ នៅឆ្នាំ២០១៨ ពោលគឺកើនឡើង ២,៩% ជាមធ្យមក្នុងមួយឆ្នាំ ដែលខ្ពស់ជាងអត្រាកំណើនរបស់ប្រជាជនកម្ពុជាដែលស្ថិតនៅក្នុងវ័យធ្វើការ ២,៧% ជាមធ្យមក្នុងមួយឆ្នាំ។ នេះមានន័យថា ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាអាចបង្កើតការងារថ្មីបន្ថែមប្រមាណជា ២៦ម៉ឺនកន្លែង ជាមធ្យមក្នុងមួយឆ្នាំ ជូនប្រជាជនវ័យក្មេងដែលឈានដល់វ័យធ្វើការជារៀងរាល់ឆ្នាំ ព្រមទាំងអ្នកមានបំណងចង់ស្វែងរកការងារ ជាពិសេសពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ ជាលទ្ធផល អនុបាតអ្នកមានការងារទៅនឹងប្រជាជន (១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការផ្តល់ការងារដល់ប្រជាជន ដែលស្ថិតនៅក្នុងវ័យធ្វើការ ឬផ្តល់ការងារដល់អ្នកចង់ស្វែងរកការងាររក្សាបានអត្រាថេរក្នុងរង្វង់ ៨០,៦% ក្នុងរយៈពេលដូចគ្នានេះ។ ប៉ុន្តែ អនុបាតនេះមានអត្រាខ្ពស់សម្រាប់បុរស (៨៦,៤%) ជាងស្ត្រី (៧៥,២%)។ ទន្ទឹមនឹងនេះ អត្រាគ្មានការងារ (១៥ឆ្នាំ+) ស្ថិតនៅក្នុងអត្រាមួយទាបជាង ១% ប៉ុន្តែអត្រាគ្មានការងាររបស់យុវជន (១៥-២៤ឆ្នាំ) ជាពិសេស យុវជនជាបុរសមានកម្រិតខ្ពស់ជាងអត្រាគ្មានការងារ (១៥ឆ្នាំ+) ដូចបង្ហាញនៅតារាងទី៣ ខាងក្រោម។

ក្នុងចំណោមការងារថ្មីបន្ថែមចំនួន ១,៣លានកន្លែង ដែលត្រូវបានបង្កើតចន្លោះឆ្នាំ២០១៣ ទៅឆ្នាំ២០១៨ មានការកើនឡើង ៨៩៤ពាន់នាក់ ស្ថិតនៅក្នុងវិស័យឧស្សាហកម្ម, ១០០៥ពាន់នាក់ នៅក្នុងវិស័យសេវាកម្ម ប៉ុន្តែការងារនៅក្នុងវិស័យកសិកម្ម ដែលមានផលិតភាពទាបជាងគេ មានការថយចុះចំនួន ៦១៧ពាន់នាក់។

**តារាងទី៣៖ សូចនាករសេដ្ឋកិច្ច និងទីផ្សារការងារសំខាន់ៗ**

| | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|
| អត្រាកំណើន ផ.ស.ស (ថ្លៃថេរឆ្នាំ២០០០)[១] | | 7.4% | 7.1% | 7.0% | 7.0% | 7.0% | 7.0% |
| ចំនួនការងារសរុប (ពាន់នាក់; ១៥ឆ្នាំ+)[២] | | 8,274 | 8,521 | 8,626 | 8,955 | 9,102 | 9,555 |
| អត្រាកំណើនការងារ[២] | | 3.6% | 3.0% | 1.2% | 3.8% | 1.6% | 5.0% |
| អត្រាចូលរួមកម្លាំងពលកម្ម (១៥ឆ្នាំ+) | សរុប | 81.0% | 80.8% | 80.9% | 81.0% | 81.0% | 81.1% |
| | ស្រី | 75.6% | 75.5% | 75.5% | 75.6% | 75.6% | 75.6% |
| | ប្រុស | 86.8% | 86.6% | 86.7% | 86.8% | 87.0% | 87.1% |
| អនុបាតអ្នកមានការងារទៅនឹងប្រជាជន(១៥ឆ្នាំ+) | សរុប | 81.8% | 80.9% | 80.1% | 80.1% | 80.1% | 80.3% |
| | ស្រី | 86.8% | 86.5% | 86.2% | 86.2% | 86.3% | 86.6% |
| | ប្រុស | 77.2% | 75.9% | 74.5% | 74.5% | 74.4% | 74.5% |
| អត្រានិកម្មភាព (១៥ឆ្នាំ+) | សរុប | 0.3% | 0.4% | 0.5% | 0.6% | 0.6% | 0.6% |
| | ស្រី | 0.2% | 0.3% | 0.4% | 0.4% | 0.4% | 0.5% |
| | ប្រុស | 0.4% | 0.5% | 0.6% | 0.7% | 0.7% | 0.7% |
| អត្រានិកម្មភាព (១៥-២៤ឆ្នាំ) | សរុប | 0.5% | 0.7% | 0.8% | 0.9% | 1.0% | 1.0% |
| | ស្រី | 0.3% | 0.5% | 0.6% | 0.6% | 0.7% | 0.7% |
| | ប្រុស | 0.6% | 0.9% | 1.0% | 1.1% | 1.2% | 1.3% |

*ប្រភព៖ ធ្វើការចងក្រងពី (១)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២)អង្កេតសង្គមសេដ្ឋកិច្ច, និង ILOSTAT database របស់អង្គការអន្តរជាតិខាងការងារ*

ទន្ទឹមនឹងនេះ ទីផ្សារការងារកម្ពុជាក៏មិនទាន់ដំណើរការបានល្អ ដោយសារបោយកម្លាំងពលកម្ម និងតម្រូវការកម្លាំងពលកម្មមិនស្មើគ្នារវាងទីប្រជុំជន និងជនបទ សេវាអន្តរកម្មការងារ និងការបែងចែកព័ត៌មានមិនទាន់មានការអភិវឌ្ឍពេញលេញរវាងអ្នកស្វែងរកការងារ និងព័ត៌មានជ្រើសរើសកម្លាំងពលកម្ម។ នេះបានធ្វើឱ្យប្រជាជនមួយចំនួនដែលមានជំនាញ និងបទពិសោធន៍ការងារស្រាប់ បានខកខានឱកាសទទួលបានការងារនៅតាមបណ្តាវិស័យសេដ្ឋកិច្ច និងរាជធានី ខេត្ត ដែលមានការរីកចម្រើនដោយសារកង្វះព័ត៌មាន។ ការណ៍នេះក៏បានចូលរួមចំណែកធ្វើឱ្យមានការធ្វើចំណាកស្រុកទៅក្រៅប្រទេសដើម្បីស្វែងរកឱកាសការងារ។

### គ. ស្ថានភាពតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មក្នុងតំបន់

ប្រសិនបើពិនិត្យលើកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចអាស៊ាន បានក្លាយជាតំបន់មួយដែលមានការរីកលូតលាស់ខ្លាំងជាងគេនៅលើពិភពលោក ជាពិសេសក្នុងការស្រូបយកការវិនិយោគទុនផ្ទាល់ពីបរទេស ប៉ុន្តែប្រទេសជាសមាជិកបច្ចុប្បន្នកំពុងស្ថិតនៅក្នុងដំណាក់កាលផ្សេងៗនៃដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងដំណាក់កាលនៃរចនាសម្ព័ន្ធប្រជាសាស្ត្រ។ ជាក់ស្តែង ចំនួនប្រជាជនឈានចូលវ័យចំណាស់កំពុងកើនឡើងច្រើន និងការធ្លាក់ចុះអត្រាកំណើតក្នុងបណ្តាប្រទេសមួយចំនួនដូចជាប្រទេសថៃ សិង្ហបុរី និងម៉ាឡេស៊ីជាដើម (ដូចបានបង្ហាញនៅរូបទី១ខាងលើ) បានធ្វើឱ្យប្រទេសទាំងនោះកំពុងមានតម្រូវការកម្លាំងពលកម្មពីបណ្តាប្រទេសផ្សេងទៀត ដើម្បីរក្សា និងកាត់បន្ថយល្បឿននៃការធ្លាក់ចុះនៃចំនួនប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ។ ទន្ទឹមនឹងនេះ ប្រទេសមួយចំនួនទៀតនៅក្នុងតំបន់ដូចជាកម្ពុជា ហ្វីលីពីន និងឥណ្ឌូនេស៊ី ជាដើម ដែលមានសក្តានុពល

កំណើននៃប្រជាជនស្ថិតនៅក្នុងវ័យធ្វើការ នឹងប្រឈមទៅនឹងការកើនឡើងនូវតម្រូវការការងារជារៀងរាល់ឆ្នាំ បានក្លាយទៅជាប្រភពក្នុងការផ្គត់ផ្គង់កម្លាំងពលកម្ម។ ការណ៍នេះ បានជំរុញឱ្យមានបម្លាស់ទីនៃពលករទេសន្តរប្រវេសន៍កាន់តែមានសន្ទុះកើនឡើង ដើម្បីបំពេញតម្រូវការ និងឱកាសការងារសមរម្យក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃបណ្ដាប្រទេសនីមួយៗ។ តារាងខាងក្រោមបង្ហាញអំពីការប៉ាន់ស្មាននៃតម្រូវការកម្លាំងពលកម្មនៅប្រទេសសិង្ហបុរី ម៉ាឡេស៊ី និងថៃ ដោយផ្អែកលើការព្យាករណ៍របស់អង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច និងសង្គម (medium scenario) អត្រាកំណើនការងារថេរ និងអត្រាចូលរួមកម្លាំងពលកម្មថេរ។ តារាងទី៤ បានបង្ហាញថា នៅចន្លោះឆ្នាំ២០២០ និងឆ្នាំ២០២៥ ប្រទេសសិង្ហបុរីត្រូវបានប៉ាន់ស្មានថានឹងមានតម្រូវការកម្លាំងពលកម្មបន្ថែមពីខាងក្រៅប្រមាណជា ១,៣លាននាក់ ដើម្បីទៅបំពេញសក្ដានុពលឱកាសការងារដែលមិនអាចបំពេញដោយកម្លាំងពលកម្មក្នុងស្រុក។ សម្រាប់ប្រទេសថៃ គឺមានតម្រូវការប្រមាណ ៣,៤លាននាក់ និងប្រទេសម៉ាឡេស៊ីប្រមាណ ០,៦លាននាក់ ក្នុងចន្លោះឆ្នាំដូចគ្នា។ ក្នុងចន្លោះឆ្នាំ២០០៥ ដល់ឆ្នាំ២០២៥ ប្រទេសទាំង៣ខាងលើនេះ គឺមានតម្រូវការកម្លាំងពលកម្មបន្ថែមពីខាងក្រៅសរុបប្រមាណជា ៦០ម៉ឺននាក់ ក្នុងមួយឆ្នាំ។

**តារាងទី៤៖ ការប៉ាន់ស្មានតម្រូវការកម្លាំងពលកម្មនៅក្នុងប្រទេសសិង្ហបុរី ថៃ និងម៉ាឡេស៊ី**

| ចំនួនតម្រូវការកម្លាំងពលកម្ម (ពាន់នាក់) | ផ្អែកលើសេណារីយ៉ូ អត្រាកំណើនការងារថេរ | | | |
|---|---|---|---|---|
| | សិង្ហបុរី | ថៃ | ម៉ាឡេស៊ី | សរុបទាំង៣ប្រទេស |
| 2005-2010 | 720 | 490 | 85 | 1,295 |
| 2010-2015 | 535 | 1,452 | -43 | 1,944 |
| 2015-2020 | 1,026 | 2,775 | 358 | 4,159 |
| 2020-2025 | 1,272 | 3,444 | 559 | 5,275 |
| សរុប | 3,553 | 8,161 | 959 | 12,673 |
| **មធ្យមក្នុងមួយឆ្នាំចន្លោះឆ្នាំ ២០០៥-២០២៥** | **178** | **408** | **48** | **634** |

*ប្រភព៖ Education, skills development, labour mobility and economic growth; an ASEAN perspective, MLVT (ផ្ទៃក្នុង)*

## ឃ. ស្ថានភាពប្រាក់ឈ្នួល

ដោយសារអតុល្យភាពប្រជាសាស្ត្រ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងតំបន់មានកម្រិតផ្សេងគ្នា កំណើនទេសន្តរប្រវេសន៍ការងារនឹងបន្តកើនឡើង ដែលអាចបណ្ដាលឱ្យកើតមានឡើងការខ្វះខាតកម្លាំងពលកម្មក្នុងប្រទេស និងការកើនឡើងប្រាក់ឈ្នួលក្នុងស្រុកលឿន។ ជាក់ស្ដែង ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង នៅក្នុងប្រទេសកម្ពុជា បានកើនឡើងជាលំដាប់ ពោលគឺ កើនឡើងពី ៨០ដុល្លារអាមេរិកនៅឆ្នាំ២០១៣ ដល់ ១៧០ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះកើនឡើងដល់ ១៨២ដុល្លារអាមេរិក។ បើធ្វើការប្រៀបធៀបជាមួយបណ្ដាប្រទេស ដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គម ប្រហាក់ប្រហែលគ្នា ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ នេះ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាបានកើនឡើងជាលំដាប់ប្រមាណជា ១៦,៦% ជាមធ្យមក្នុងមួយឆ្នាំ ឬ កើនឡើងជិត ២ដង។ ជាលទ្ធផល គម្លាតនៃប្រាក់ឈ្នួលអប្បបរមារវាងកម្ពុជា និងប្រទេសទទួលពលករកម្ពុជាបានកាត់

បន្ថយជាបណ្តើរៗ ប៉ុន្តែកម្លាតនេះនៅមានកម្រិតខ្ពស់។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ ប្រាក់ឈ្នួលអប្បបរមា ក្នុងមួយខែនៅ៖

- ប្រទេសថៃ គឺចន្លោះពី ២៤៨ ទៅ ២៦៦ដុល្លារអាមេរិក
- ប្រទេសម៉ាឡេស៊ី គឺប្រមាណ ២៩០ដុល្លារអាមេរិក
- ប្រទេសអារ៉ាប់ប៊ីសាអូឌីត គឺប្រមាណ ៣៤៧ដុល្លារអាមេរិក
- តំបន់រដ្ឋបាលពិសេសហុងកុងនៃប្រទេសចិន គឺប្រមាណ ៧៣៩ដុល្លារអាមេរិក
- ប្រទេសសិង្ហបុរី គឺប្រមាណ ៨៩០ដុល្លារអាមេរិក (មិនអនុវត្តសម្រាប់កម្មករការងារផ្ទះ)
- សាធារណរដ្ឋកូរ៉េ គឺប្រមាណ ១ ៣៩៧ដុល្លារអាមេរិក
- ប្រទេសជប៉ុន គឺចន្លោះពី ១ ៤០០ ទៅ ១ ៨០០ដុល្លារអាមេរិក។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសទទួលពលករ អាចនឹងធ្វើការកែសម្រួលប្រាក់ឈ្នួលរបស់ខ្លួនជាបន្តបន្ទាប់ ដែលអាចធ្វើឱ្យកត្តាលម្អៀងនៃប្រាក់ឈ្នួលនេះ នៅតែជាកត្តាកំណត់មួយ ក្នុងការទាក់ទាញឱ្យមានការធ្វើទេសន្តរប្រវេសន៍ការងារ។

**រូបភាពទី២៖ ប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជា និងប្រទេសគោលដៅសម្រាប់ឆ្នាំ២០១៨**




*ប្រភព៖ ចងក្រងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ដូចក្នុងបរិការណ៍ និងនិន្នាការដែលបានបង្ហាញខាងលើ ទេសន្តរប្រវេសន៍ការងារគឺជាកត្តាដែលមិនចៀសផុតបាន ហើយបានក្លាយជាយុទ្ធសាស្ត្រដ៏សំខាន់មួយសម្រាប់ប្រទេសទាំងអស់រួមទាំងកម្ពុជា ដើម្បីធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់។

**២.២- និន្នាការនៃទេសន្តរប្រវេសន៍ការងារកម្ពុជា**

រូបភាព និងចរិតលក្ខណៈរបស់ទេសន្តរប្រវេសន៍ការងារកម្ពុជា មានការផ្លាស់ប្តូរ និងប្រែប្រួលគួរឱ្យកត់សម្គាល់នៅក្នុងរយៈពេល ៣ទស្សវត្សរ៍ចុងក្រោយនេះ។ មុនឆ្នាំ១៩៩៧ មូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍ គឺដោយសារបញ្ហាសង្គ្រាម អស្ថិរភាពផ្នែកនយោបាយ និងកង្វះទីផ្សារការងារវិស័យឧស្សាហកម្ម។ ប៉ុន្តែបន្ទាប់ពីការអនុវត្តដោយជោគជ័យនូវនយោបាយ ឈ្នះ-ឈ្នះ និងទទួលបានសន្តិភាពទូទាំងប្រទេស ភាគច្រើននៃទេសន្តរប្រវេសន៍ គឺក្នុងគោលបំណងស្វែងរកឱកាសការងារល្អប្រសើរ។ ទោះបីជាមានការកើនឡើងនៃចំនួនទេសន្តរប្រវេសន៍ ប៉ុន្តែទេសន្តរប្រវេសន៍កម្ពុជា គឺស្ថិតនៅក្នុងដំណាក់កាលដំបូង ពោលគឺជាវិធីសាស្ត្ររយៈពេលខ្លីរបស់ប្រជាជននៅទីជនបទ សម្រាប់ដោះស្រាយបញ្ហាចំណូលនៅក្នុងគ្រួសារ និងទប់ទល់ទៅនឹងហានិភ័យដែលកើតឡើងដោយមិនបានព្រាងទុក ក៏ដូចជាការចង់ដឹង ចង់ឃើញនូវវប្បធម៌ និងការរីកចម្រើននៅប្រទេសផ្សេងទៀត។

ស្របគ្នានឹងសន្ទុះនៃទេសន្តរប្រវេសន៍ក្នុងប្រទេស ជាពិសេសការធ្វើចំណាកស្រុកពីជនបទទៅទីប្រជុំជនដោយសារការរីកចម្រើននៃវិស័យឧស្សាហកម្ម និងសេវាកម្ម ព្រមទាំងការពង្រីកទីក្រុង និន្នាការនៃទេសន្តរប្រវេសន៍ទៅក្រៅប្រទេសក៏បានកើនឡើងផងដែរ។ គិតត្រឹមឆ្នាំ២០១៨ ពលករកម្ពុជាដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេសដោយស្របច្បាប់ តាមរយៈទីភ្នាក់ងារជ្រើសរើស ដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនប្រមាណ ១,២៣លាននាក់ (ស្រី ៤៩៩ ០៧០នាក់) ដែលក្នុងនោះនៅប្រទេសថៃមានចំនួន ១ ១៤៦ ៦៨៥នាក់ (ស្រី ៤៥៨ ០២៧នាក់) (ពលករដែលត្រូវបានផ្តល់ភាពស្របច្បាប់មានចំនួន ៩៩៥ ៣៧១នាក់) សាធារណរដ្ឋកូរ៉េចំនួន ៤៩ ០៩៩នាក់ (ស្រី ១០ ៤០៣នាក់) ប្រទេសជប៉ុនចំនួន ៩ ១៩៥នាក់ (ស្រី ៣ ៨៦៧នាក់) ម៉ាឡេស៊ីចំនួន ៣០ ១១៣នាក់ (ស្រី ២៥ ៨៧២នាក់) សិង្ហបុរីចំនួន ៨៣១នាក់ (ស្រី ៨៣១នាក់) អារ៉ាប់ប៊ីសាអូឌីតចំនួន ១៦នាក់ (ស្រី ១៦នាក់) និងតំបន់រដ្ឋបាលពិសេសហុងកុងនៃប្រទេសចិនចំនួន ៥៤នាក់ (ស្រី ៥៤នាក់)។

បើយោងតាមការប៉ាន់ស្មានរបស់ធនាគារពិភពលោក ប្រាក់បញ្ញើរបស់ពលករកម្ពុជានៅបរទេសត្រឡប់ចូលមកក្នុងកម្ពុជានៅក្នុងឆ្នាំ២០១៨ គឺប្រមាណ ១,៤៣ ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ៥,៨% នៃ ផ.ស.ស ដែលកើនឡើងប្រមាណជា ៤២,៩% ពី ១ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៣។ ការអង្កេតដែលបានធ្វើឡើងដោយអង្គការ ILO និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ក្នុងឆ្នាំ២០១៧ បានរកឃើញថាពលករស្ទើរតែទាំងអស់ បានផ្ញើប្រាក់ត្រឡប់មកប្រទេសកម្ពុជាវិញ ប៉ុន្តែចំនួនទឹកប្រាក់ដែលផ្ញើត្រឡប់មកផ្ទះវិញ គឺមានការប្រែប្រួលទៅតាមកម្រិតនៃការអភិវឌ្ឍ និងកម្រិតនៃប្រាក់ខែ ដែលទទួលបាននៅក្នុងប្រទេសទទួល។ តាមការប៉ាន់ប្រមាណរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើប្រាក់ឈ្នួលគោលនៃប្រទេសនីមួយៗ ក្នុងឆ្នាំ២០១៨ ពលករទេសន្តរប្រវេសន៍កម្ពុជា អាចសន្សំប្រាក់ និងផ្ញើមកក្រុមគ្រួសារបានប្រមាណជា ២,៣ពាន់លានដុល្លារអាមេរិក ដោយក្នុងនោះពីប្រទេសថៃប្រមាណជា ១,៩ពាន់លានដុល្លារអាមេរិក, ពីសាធារណរដ្ឋកូរ៉េប្រមាណជា ៣០០ លានដុល្លារអាមេរិក, ពីប្រទេសជប៉ុនប្រមាណជា ៨០លានដុល្លារអាមេរិក, ពីប្រទេសម៉ាឡេស៊ីប្រមាណជា ៥០លានដុល្លារអាមេរិក, ពីប្រទេសសិង្ហបុរីប្រមាណជា ២លានដុល្លារអាមេរិក។

ទន្ទឹមនឹងនេះ ពលករទេសន្តរប្រវេសន៍មួយចំនួន ក៏មិនទាន់បានប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ផ្ញើប្រាក់ត្រឡប់មកគ្រួសារវិញ និងបានកំពុងប្រើប្រាស់ការផ្ញើប្រាក់តាមប្រព័ន្ធមិនផ្លូវការ ដែលអាចប្រឈមនឹងការបាត់បង់ប្រាក់ ឬការចំណាយថ្លៃសេវាផ្ញើប្រាក់ខ្ពស់។ ការប្តូរពីប្រព័ន្ធមិនផ្លូវការមកប្រព័ន្ធផ្លូវការ នឹងចូលរួមកាត់បន្ថយចំណាយក្នុងការផ្ញើប្រាក់របស់ពលករទេសន្តរប្រវេសន៍ និងលុបបំបាត់ប្រព័ន្ធផ្ញើប្រាក់ក្រៅផ្លូវការ ដែលគិតថ្លៃសេវាខ្ពស់។ បន្ថែមពីលើនេះ ការគ្រប់គ្រង ការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍កម្ពុជានៅក្រៅប្រទេស ក៏ជាបញ្ហាសំខាន់ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ។

ឱកាសការងារនៅក្រៅប្រទេស ដែលផ្សាភ្ជាប់ជាមួយនឹងការទទួលស្គាល់ជំនាញ ក៏ដូចជាការផ្ទេរអត្ថប្រយោជន៍របបសន្តិសុខសង្គមរបស់ពលករដែលត្រឡប់ ឬដែលបញ្ចប់កិច្ចសន្យាការងារនៅក្រៅប្រទេស គឺជាចក្ខុវិស័យថ្មី ដែលរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាភាគីពាក់ព័ន្ធផ្តើមឱ្យមានការយកចិត្តទុកដាក់។ ជាក់ស្តែងប្រទេសកម្ពុជា និងប្រទេសថៃ បានឯកភាពឱ្យមានការទទួលស្គាល់ជំនាញចំនួន២ គឺការងារកំបោរ និងការតបណ្តាញអគ្គិសនីក្នុងអគារ។ ដោយឡែក នៅសាធារណរដ្ឋកូរ៉េ កម្ពុជាបានចូលរួម និងជំរុញឱ្យភាគីកូរ៉េបន្ត និងពង្រីកកម្មវិធី Happy Return Program ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់ពលករមុនពេលត្រឡប់ ឬក្រោយពេលត្រឡប់មកដល់កម្ពុជាវិញ ផ្តល់ប្រឹក្សាយោបល់អំពីទីផ្សារការងារ និងផ្តល់សេវាការងារនៅតាមរោងចក្រ សហគ្រាសកូរ៉េដែលមកវិនិយោគនៅកម្ពុជា និងសម្របសម្រួលស្នើសុំប្រាក់ធានារ៉ាប់រងជូនពលករស្របច្បាប់ ដែលបានត្រឡប់មកដល់ប្រទេសកម្ពុជាវិញ។ ដូចគ្នានេះដែរ សម្រាប់ប្រទេសជប៉ុន កម្ពុជាគាំទ្រកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកទេស ក្រោមរូបភាពបញ្ជូនកម្មសិក្សាការីឱ្យទៅធ្វើកម្មសិក្សាផង និងធ្វើការងារផងក្នុងអំឡុងពេលស្នាក់នៅប្រទេសជប៉ុន ដើម្បីបង្កើននូវជំនាញ សម្រាប់មកបម្រើការងារជូនរោងចក្រ សហគ្រាសដើមវិញ។ ជាមួយគ្នានេះ កម្ពុជាក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តួចផ្តើមរៀបចំឱ្យមានចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍នៃបណ្តាប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ាថៃ និងវៀតណាម (CLMTV) ដែលជាចំណុចផ្តើម ដើម្បីពង្រីកទៅដល់គ្រប់រដ្ឋជាសមាជិកអាស៊ាន។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជា កូរ៉េ និងថៃ បានកំពុងអនុវត្តការផ្ទេរនូវអត្ថប្រយោជន៍នៃការធានារ៉ាប់រងផ្នែកគ្រោះថ្នាក់ការងារដល់ក្រុមគ្រួសារពលករនៃប្រទេសនីមួយៗរួចហើយដែរ។

## ៣- និន្នាការទេសន្តរប្រវេសន៍ការងារ

នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ចំនួនពលករទេសន្តរប្រវេសន៍មានការកើនឡើងយ៉ាងខ្លាំង ដែលក្នុងនោះការធ្វើទេសន្តរប្រវេសន៍ការងារ ពីតំបន់អាស៊ីខាងត្បូងកាន់តែមានភាពលេចធ្លោឡើង។ តាមការប៉ាន់ប្រមាណមានពលករទេសន្តរប្រវេសន៍ចំនួន ២១លាននាក់ ដែលមានប្រភពមកពីប្រទេសនៃតំបន់អាស៊ាន ធ្វើទេសន្តរប្រវេសន៍ការងារទៅតាមបណ្តាប្រទេស និងតំបន់ផ្សេងៗទៀតក្នុងពិភពលោក។ ក្នុងចំណោមពលករទាំងអស់នោះ មានពលករចំនួន ៦,៨លាននាក់ បានធ្វើទេសន្តរប្រវេសន៍ទៅកាន់បណ្តាប្រទេសផ្សេងៗនៅក្នុងតំបន់អាស៊ានដូចគ្នា។ និន្នាការទេសន្តរប្រវេសន៍ការងារនៅក្នុងប្រទេសកម្ពុជា ក៏មានលក្ខណៈស្របគ្នាទៅនឹងនិន្នាការថ្នាក់តំបន់ផងដែរ ដោយមានពលករកម្ពុជាបានធ្វើទេសន្តរប្រវេសន៍ការងារ ទៅបណ្តាប្រទេសផ្សេងៗនៅក្នុង និងក្រៅតំបន់អាស៊ាន។ សម្រាប់កម្ពុជា ការធ្វើទេសន្តរប្រវេសន៍ការងារដោយស្របច្បាប់និងផ្លូវការ បានចាប់ផ្តើម

ឡើងបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស។

## ៣.១- ក្របខណ្ឌគោលនយោបាយ

ក្នុងការរួមចំណែកការពារ លើកកម្ពស់សិទ្ធិ និងគ្រប់គ្រងពលករទេសន្តប្រវេសន៍ប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធ មានជាអាទិ៍៖

១- កម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព

២- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

៣- ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥

៤- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣

៥- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥

៦- គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥

៧- កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣។

## ៣.២- ក្របខណ្ឌគតិយុត្តជាតិ

ដោយអនុវត្តតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៣ ស្តីពីសិទ្ធិ និងករណីយកិច្ចប្រជាពលរដ្ឋខ្មែរ និងច្បាប់ស្តីពីការងារ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទដ្ឋានគតិយុត្តជាច្រើន ដើម្បីពង្រឹងការគ្រប់គ្រងទេសន្តប្រវេសន៍ការងារឱ្យមានប្រសិទ្ធភាព។

នៅក្នុងខែសីហា ឆ្នាំ២០១១ រាជរដ្ឋាភិបាលបានកែសម្រួលអនុក្រឹត្យលេខ៥៧ អនក្រ.បក ដោយអនុក្រឹត្យលេខ១៩០ អនក្រ.បក ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន។ អនុក្រឹត្យនេះជាក្របខណ្ឌគតិយុត្តដ៏សំខាន់មួយ សម្រាប់ការគ្រប់គ្រង និងការការពារពលករទេសន្តប្រវេសន៍កម្ពុជា។ ដើម្បីពង្រឹងការអនុវត្តអនុក្រឹត្យលេខ១៩០ អនក្រ.បក នេះ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញប្រកាសចំនួន៨ នៅឆ្នាំ២០១៣។ ប្រកាសទាំងនោះត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយដៃគូត្រីភាគីបូក និងជំនួយបច្ចេកទេសពីអង្គការ ILO ដោយបានយកចិត្តទុកដាក់ជាពិសេសលើសមភាពយេនឌ័រផងដែរ។ ប្រកាសទាំង ៨ នោះរួមមាន៖

- ប្រកាសលេខ០៤៥/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់ពាក្យគន្លឹះនៅក្នុងអនុក្រឹត្យលេខ១៩០ អនក្រ.បក
- ប្រកាសលេខ០៤៦/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីដំណើរការជ្រើសរើសនិងការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ
- ប្រកាសលេខ០៤៧/១៣ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីទីភ្នាក់ងារជ្រើសរើសឯកជន

- ប្រកាសលេខ២៤៩ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីយន្តការទទួលពាក្យបណ្តឹងពលករទេសន្តប្រវេសន៍
- ប្រកាសលេខ២៥០ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសលេខ២៥១ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសលេខ២៥២ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីសេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍
- ប្រកាសលេខ២៥៣ ក.ប/ប្រ.ក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យប្រើប្រាស់បទដ្ឋានអប្បបរមាកិច្ចសន្យាសេវារកការងារឱ្យធ្វើនៅបរទេស។

ដោយសារមានការកើនឡើងនៃចំនួនទេសន្តរប្រវេសន៍ការងារ និងភាពស្មុគស្មាញនៃការធ្វើទេសន្តរប្រវេសន៍ការងារ តម្រូវឱ្យកម្ពុជាត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តខ្ពស់ជាងនេះ ដើម្បីពង្រឹងប្រសិទ្ធភាព និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។

**៣.៣- លិខិតូបករណ៍អន្តរជាតិ**

កម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW-១៩៧៩) នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩២ និងបានអនុម័តយល់ព្រមលើពិធីសារតាមជម្រើស (Optional Protocol-១៩៩៩) នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ និងអនុសាសន៍ទូទៅលេខ២៦ ស្តីពីពលករទេសន្តប្រវេសន៍ ជាស្ត្រី ដោយបានកំណត់ពីកាតព្វកិច្ចរបស់ភាគីរដ្ឋាភិបាលក្នុងការគោរព ការការពារ និងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សចំពោះពលករទេសន្តប្រវេសន៍ជាស្ត្រី។

កម្ពុជា គឺជារដ្ឋសមាជិកមួយរបស់អង្គការសហប្រជាជាតិក្នុងចំណោមរដ្ឋសមាជិកសរុបទាំង ១៩៣ ដែលបានអនុម័តនៅ ឆ្នាំ២០១៥ នូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals-SDGs) ដែលបញ្ហាទេសន្តប្រវេសន៍ការងារត្រូវបានបញ្ជាក់នៅក្នុង**ចំណុច ៥.២** "ការលុបបំបាត់គ្រប់រូបភាពនៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅទីសាធារណៈនិងឯកជន រួមទាំងការជួញដូរមនុស្សនិងផ្លូវភេទ និងការកេងប្រវ័ញ្ចផ្សេងៗទៀត", **ចំណុច ៨.៥** "ការសម្រេចបានការងារសមរម្យ និងការងារដែលមានផលិតភាពពេញលេញសម្រាប់បុរស ស្ត្រី រួមទាំងជនវ័យក្មេង និងជនពិការ ក៏ដូចជាប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា", **ចំណុច ៨.៧** "ការចាត់វិធានការបន្ទាន់និងមានប្រសិទ្ធភាពលុបបំបាត់ការងារដោយបង្ខំ ការបញ្ចប់ការងារទាសភាព ការជួញដូរមនុស្ស ធានាការហាមឃាត់ និងការលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនិងការជ្រើសរើសនិងប្រើពលកម្មកុមារគ្រប់រូបភាព", **ចំណុច ៨.៨** "ការការពារសិទ្ធិ ការលើកកម្ពស់សុវត្ថិភាព និងការធានាបរិយាកាសល្អក្នុងការងារសម្រាប់ពលករទាំងអស់ រួមទាំងពលករទេសន្តប្រវេសន៍ ជាពិសេស ពលករទេសន្តប្រវេសន៍ជាស្ត្រី និងពលករស្ថិតនៅក្នុងមុខរបរដែលមិនទៀងទាត់",**ចំណុច ១០.៧** "សម្រួលទេសន្តប្រវេសន៍ និងចលនាប្រជាជនឱ្យមានសណ្តាប់ធ្នាប់ សុវត្ថិភាព និងការទទួលខុសត្រូវ ដោយការអនុវត្តផែនការសកម្មភាពគោលនយោបាយទេសន្តប្រវេសន៍" និង**ចំណុច ១០.C** "កាត់បន្ថយថ្លៃសេវាផ្ទេរ

ប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍ឱ្យនៅទាបជាង ៣% និងលុបបំបាត់ការផ្ញើប្រាក់ក្រៅប្រព័ន្ធធនាគារ ដែលមានតម្លៃខ្ពស់ជាង ៥% នៅត្រឹមឆ្នាំ២០៣០"។

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ កម្ពុជាបានចូលរួមជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិ ស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ (១៩៩០) ដែលបានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣។ ជាមួយគ្នានេះកម្ពុជា ក៏បានយកចិត្តទុកដាក់ អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញា/កតិកាសញ្ញារបស់អង្គការអន្តរជាតិ និងអង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារផ្សេងៗ ដោយបានបញ្ចូលចំណុចគន្លឹះនៃអនុសញ្ញា និងកតិកាសញ្ញាទាំងអស់នេះចូលទៅក្នុងបទប្បញ្ញត្តិជាតិ ជាពិសេស បទប្បញ្ញត្តិដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ លិខិតូបករណ៍អន្តរជាតិ ដែលកម្ពុជាយកធ្វើជាមូលដ្ឋាន រួមមាន៖

- កតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់
- អនុសញ្ញាអន្តរជាតិខាងការងារលេខ៩៧ ស្តីពីទេសន្តរប្រវេសន៍ដើម្បីការងារ (ត្រូវបានកែសម្រួលក្នុងឆ្នាំ១៩៤៩)
- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៤៣ ស្តីពីទេសន្តរប្រវេសន៍ក្នុងលក្ខខណ្ឌរំលោភបំពាន និងការលើកកម្ពស់សមភាពនៃកាលានុវត្តភាព និងប្រព្រឹត្តកម្មលើពលករទេសន្តរប្រវេសន៍ (១៩៧៥)
- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨១ ស្តីពីភ្នាក់ងារមុខរបរឯកជន (១៩៩៧)
- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨៨ ស្តីពីការងារនេសាទ (២០០៧)
- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨៩ និងអនុសាសន៍លេខ២០១ ស្តីពីកម្មករការងារផ្ទះ (២០១១)។

### ៣.៤- លិខិតូបករណ៍ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់-ទ្វេភាគី

កម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអាស៊ានស្តីពីបម្លាស់ទីរូបវន្តបុគ្គលនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៤។ កិច្ចព្រមព្រៀងនេះ មានគោលបំណង (១) ផ្តល់សិទ្ធិ និងកាតព្វកិច្ច ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះបន្ថែមទៅអ្វី ដែលមានចែងក្នុងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម និងពិធីសារសម្រាប់អនុវត្តកិច្ចព្រមព្រៀងនោះ ពាក់ព័ន្ធនឹងបម្លាស់ទីរូបវន្តបុគ្គលរវាងរដ្ឋជាសមាជិកទាំងឡាយ (២) សម្រួលការបម្លាស់ទីរបស់រូបវន្តបុគ្គលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ រវាងរដ្ឋជាសមាជិកទាំងឡាយ (៣) បង្កើតនីតិវិធីនានា ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពសម្រាប់ការដាក់ពាក្យសុំបែបបទអន្តោប្រវេសន៍សម្រាប់ការចូលមក និងស្នាក់នៅជាបណ្តោះអាសន្នរបស់រូបវន្តបុគ្គល ដែលស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ និង (៤) ការពារបូរណភាពព្រំដែនរបស់រដ្ឋជាសមាជិកទាំងឡាយ និងការពារកម្លាំងពលកម្មក្នុងស្រុក និងការងារជាអចិន្ត្រៃយ៍ក្នុងដែនដីរបស់រដ្ឋជាសមាជិកទាំងឡាយ។

នៅឆ្នាំ២០១៦ ប្រទេសកម្ពុជា បានចូលជាសមាជិកនៃយន្តការកូឡុំបូ (Colombo Process) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ ហើយដែលជាយន្តការពិគ្រោះយោបល់ថ្នាក់តំបន់ក្នុងចំណោមបណ្តាប្រទេសបញ្ជូនចំនួន១២ ស្តីពីការគ្រប់គ្រងមុខរបរនិងការងារនៅក្រៅប្រទេស សម្រាប់ប្រទេសបញ្ជូនពលករនៅអាស៊ី ដើម្បីសម្របសម្រួលកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការលើបញ្ហាដែលជាផលប្រយោជន៍រួម និងកង្វល់ផ្សេងៗ

ទាក់ទងនឹងការបម្លាស់ទីរបស់ពលករ។

ក្នុងនាមជាសមាជិកអាស៊ាន រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញារួមគ្នាក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ស្របតាមសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ASEAN Declaration on the Protection and Promotion of the Rights of Migrant Workers) ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ និងឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ (ASEAN Consensus on the Protection and Promotion of the Rights of Migrant Workers) ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

ជាមួយគ្នានេះ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) បានផ្តួចផ្តើម និងអនុវត្តកិច្ចសហប្រតិបត្តិការលើវិស័យការងារ ដែលក្នុងនោះមានការពិភាក្សាលើការការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។ ការពិភាក្សានោះបានឈានទៅដល់ការព្រមព្រៀងគ្នា ក្នុងការបង្កើតឱ្យមានសេចក្តីថ្លែងការណ៍រួមរដ្ឋមន្ត្រីការងារ CLMTV ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍នៃប្រទេសទាំង៥។

ក្រៅពីនេះ កម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងទ្វេភាគីជាមួយបណ្តាប្រទេសចំនួន១៣ រួមមានប្រទេសថៃ សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ី ប្រទេសសិង្ហបុរី តំបន់រដ្ឋបាលពិសេសហុងកុងនៃប្រទេសចិន ប្រទេសអារ៉ាប់ប៊ីសាអូឌីត រដ្ឋគូវ៉ែត រដ្ឋកាតា ប្រទេសវៀតណាម ប្រទេសទីម័រឡេស្តេ ប្រទេសហ្វីលីពីន និងប្រទេសបង់ក្លាដែស (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣)។

### ៣.៥- ក្របខណ្ឌស្ថាប័ន

អនុក្រឹត្យលេខ ១៩០ អនក្រ.បក ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន បានកំណត់ឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ។

ក្នុងការអនុវត្តភារកិច្ចនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានសហការយ៉ាងជិតស្និទ្ធជាមួយស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុលកម្ពុជាប្រចាំប្រទេសទទួល ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ រដ្ឋបាលរាជធានី ខេត្ត អង្គការ ILO អង្គការ IOM អង្គការ UN Women អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ឱ្យមានទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារប្រចាំនៅស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួល ដើម្បីសម្របសម្រួលគ្រប់គ្រង ការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសទទួល ដែលក្នុងនោះរួមមាននៅប្រទេសថៃ សាធារណៈរដ្ឋកូរ៉េ ប្រទេសម៉ាឡេស៊ី និងប្រទេសជប៉ុន។

យោងតាមអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថានតំណាងរបស់ព្រះរាជាណាចក្រកម្ពុជានៅបរទេស អនុព័ន្ធការងារត្រូវបានរំលេចជារចនា

សម្ព័ន្ធផ្លូវការមួយនៅអមស្ថានតំណាងទាំងនោះ ដែលយោងតាមអនុក្រឹត្យចាស់គឺមិនមានរំលេចឡើយ។ តាមរយៈអនុក្រឹត្យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងកំណត់ភារកិច្ចលម្អិតដល់ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ ស្របតាមគោលនយោបាយសង្ខេបរបស់អង្គការ ILO ស្តីពីតួនាទីរបស់ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារនៃតំបន់អាស៊ានក្នុងការការពារពលករទេសន្តរប្រវេសន៍ (ILO Policy Brief Issue No.1 on The role of ASEAN labour attaché in the protection of migrant workers) ដូចមាននៅក្នុងឧបសម្ព័ន្ធ ៤។

## ៤- បញ្ហាប្រឈម

ជាមួយការខិតខំអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៤-២០១៨ ដោយទទួលបានលទ្ធផលធំៗគួរជាទីមោទនៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏នៅជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ និងដោះស្រាយរួមមាន៖

- មិនទាន់មានច្បាប់ និងគោលនយោបាយថ្នាក់ជាតិសម្រាប់គ្រប់គ្រងទេសន្តរប្រវេសន៍ការងារ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យទេសន្តរប្រវេសន៍ការងារនៅមានកម្រិត
- ការសហការជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធមិនទាន់បានពេញលេញ
- ទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួនមិនទាន់បានបំពេញតួនាទីរបស់ខ្លួនបានពេញលេញ ដោយការយល់ដឹង និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានា ព្រមទាំងសមត្ថភាពបុគ្គលិករបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅមានកម្រិត និងធ្វើការផ្សព្វផ្សាយពីការជ្រើសរើសពលករទៅធ្វើការនៅបរទេសដោយគ្មាន ឬលើសពីការអនុញ្ញាតរបស់ក្រសួង
- ការអប់រំណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរមិនទាន់បានគ្រប់គ្រាន់
- ការងារនៅប្រទេសគោលដៅមួយចំនួន ជាការងារគ្មានជំនាញ ឬជំនាញទាប
- ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារមិនទាន់មាននៅគ្រប់បណ្តាប្រទេសទទួល
- កង្វះខាតយន្តការទទួលស្គាល់ជំនាញពលករពេលវិលត្រឡប់មកមាតុប្រទេសវិញ
- មិនទាន់មានយន្តការសម្របសម្រួលជាមួយគ្រួសារពលករ
- មិនទាន់មានយន្តការសមាហរណកម្មពលករទៅក្នុងសហគមន៍
- មិនទាន់បានរៀបចំយន្តការគ្រប់គ្រងការផ្ទេរតាវកាលិករបបសន្តិសុខសង្គមពីបណ្តាប្រទេសដែលមានពលករទេសន្តរប្រវេសន៍កម្ពុជា។

## ៥- ចក្ខុវិស័យ

ចក្ខុវិស័យរបស់គោលនយោបាយនេះ គឺដើម្បីពង្រឹងយន្តការគ្រប់គ្រង ការពារ និងលើកកម្ពស់សិទ្ធិនិងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព សំដៅជានាការទទួលបានឱកាសការងារសមរម្យ ការអភិវឌ្ឍជំនាញ ចំណេះដឹង បទពិសោធន៍ ធនធាន និងអត្ថប្រយោជន៍នៃកិច្ចគាំពារសង្គមដល់ពលករ សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។

## ៦- គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ គោលនយោបាយនេះត្រូវបានរៀបចំឡើង ដោយកំណត់គោលបំណង គោលដៅ និងវិធានការជំរស់រើកថ្មីៗបន្ថែមទៀត ដែលអាចវាស់វែង និងវាយតម្លៃបានច្បាស់លាស់។

### ៦.១- គោលបំណង

គោលនយោបាយនេះ មានគោលបំណងចម្បងៗចំនួន ៣៖

**គោលបំណងទី១ ៖** ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ

**គោលបំណងទី២ ៖** ការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍

**គោលបំណងទី៣ ៖** ការផ្សាភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

### ៦.២- គោលដៅ

ដើម្បីសម្រេចបានគោលបំណងទី១ "**ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ**" គោលនយោបាយនេះ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

គោលដៅ១.១៖ ធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ

គោលដៅ១.២៖ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ

គោលដៅ១.៣៖ ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

គោលដៅ១.៤៖ បន្តកសាងសមត្ថភាពមន្ត្រី និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ និងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

គោលដៅ១.៥៖ ប្រមូល ចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍

គោលដៅ១.៦៖ បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ ( Migrant Resources Center - MRC) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដើម្បីសម្រេចបានគោលបំណងទី២ "**ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍**" គោលនយោបាយនេះ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

គោលដៅ២.១៖ ពង្រឹង និងពង្រីកសេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល នៅបណ្តាប្រទេសទទួល

គោលដៅ២.២៖ ពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងពលករទេសន្តរប្រវេសន៍

គោលដៅ២.៣៖ ចងក្រង ផលិត បោះពុម្ពឯកសារ និងផ្សព្វផ្សាយអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពឱ្យបានទូលំទូលាយ

គោលដៅ២.៤៖ ពង្រឹង និងពង្រីកយន្តការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីកិច្ចគាំពារសង្គមដល់ពលករទេសន្តរប្រវេសន៍

ដើម្បីសម្រេចបានគោលបំណងទី៣ "**ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច**" គោលនយោបាយនេះ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

គោលដៅ៣.១៖ លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍

គោលដៅ៣.២៖ ពង្រឹងយន្តការគាំទ្រគ្រួសារពលករ និងយន្តការសមាហរណកម្មពលករទេសន្តរប្រវេសន៍ក្នុងសហគមន៍

គោលដៅ៣.៣៖ ពង្រីកទីផ្សារការងារដែលមានជំនាញ លើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមុនពេលចេញដំណើរ និងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍

## ៧- យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ នឹងឆ្លើយតបទៅនឹងបញ្ហាក្នុងការអនុវត្តកន្លងមក និងកំណត់នូវផែនការសកម្មភាពច្បាស់លាស់ ដែលមានការសម្របសម្រួល ប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមកដើម្បីធានាប្រសិទ្ធភាព និងជោគជ័យនៃការអនុវត្តគោលនយោបាយ។

### ៧.១- គោលបំណងទី១៖ ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ

អភិបាលកិច្ចទេសន្តរប្រវេសន៍ការងារដោយជោគជ័យ និងមានប្រសិទ្ធភាព ទាមទារឱ្យមានការបង្កើតច្បាប់ និងកែសម្រួលបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ ព្រមទាំងមានការចូលរួមពីក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិ និងដៃគូពាក់ព័ន្ធដទៃទៀត ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងការអនុវត្ត។

### ៧.១.១- គោលដៅ១.១៖ ធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ

ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ រាជរដ្ឋាភិបាលរៀបចំឱ្យមានការពិនិត្យកែសម្រួល និងកសាងបទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ ដោយមានការយកចិត្តទុកដាក់លើយេនឌ័រផងដែរ ស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម។ រាជរដ្ឋាភិបាលកម្ពុជានឹងសិក្សាលទ្ធភាពក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដោយស្របតាមបរិបទកម្ពុជា។

**វិធានការ៖**

១-កសាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារនៅបរទេស។

២-បង្កើនការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនានាអំពីបទដ្ឋានជាតិនិងអន្តរជាតិទាក់ទងនឹងទេសន្តរប្រវេសន៍ការងារ ជាពិសេសឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ព្រមទាំងឧត្តមានុវត្ត នៅថ្នាក់តំបន់ ឬអន្តរជាតិ។

៣-ពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងសិក្សាពីលទ្ធភាពក្នុងការផ្តល់សច្ចាប័នលើបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធនានាដូចជា អនុសញ្ញាអន្តរជាតិខាងការងារលេខ ៩៧, លេខ ១៤៣, លេខ ១៨១,

លេខ ១៨៨, លេខ ១៨៩, ពិធីសារស្តីពីការងារដោយបង្ខំ និងអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ដោយស្របតាមបរិបទកម្ពុជា។

៤-លើកកម្រិតគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ឱ្យទៅជាគោលនយោបាយថ្នាក់ជាតិ។

### ៧.១.២- គោលដៅ១.២៖ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ

រាជរដ្ឋាភិបាលកម្ពុជាបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ ជាពិសេសក្នុងក្របខណ្ឌអាស៊ានជាមួយនឹងចក្ខុវិស័យច្បាស់លាស់ ដែលកំណត់នៅក្នុងឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងតាមរយៈការចុះកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា ដោយផ្តោតលើលក្ខខណ្ឌទូទៅនៃការងារ កិច្ចគាំពារសង្គម អត្ថប្រយោជន៍ផ្សេងៗរបស់ពលករទេសន្តរប្រវេសន៍ និងសមភាពយេនឌ័រ។

**វិធានការ៖**

១-រៀបចំកិច្ចពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។

២-ចូលរួមកិច្ចពិគ្រោះយោបល់នៅថ្នាក់តំបន់ និងរៀបចំលិខិតូបករណ៍ពាក់ព័ន្ធនឹងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ ដូចជាការចូលរួម និងផ្តល់អនុសាសន៍ក្នុងវេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ។

៣-ចូលរួមសហការពង្រឹងប្រព័ន្ធគ្រប់គ្រងស្ថិតិទេសន្តរប្រវេសន៍ការងារអាស៊ាន និងធ្វើការវិភាគទិន្នន័យដែលប្រមូលបាន ដើម្បីប្រើប្រាស់សម្រាប់ការរៀបចំគោលនយោបាយនានា។

៤-បន្តកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសបញ្ជូន ដើម្បីពង្រឹងតួនាទី និងការអនុវត្តល្អៗលើអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ។

៥-ពង្រឹងកិច្ចសហប្រតិបត្តិការរវាងដៃគូអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដើម្បីធ្វើការចែករំលែកបទពិសោធន៍ និងសកម្មភាពការងារ ចៀសវាងការអនុវត្តសកម្មភាពត្រួតគ្នា និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន។

៦-ចុះកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (MOU) លើកិច្ចសហប្រតិបត្តិការទេសន្តរប្រវេសន៍ការងារជាមួយបណ្តាប្រទេសនានា ដោយផ្តោតលើលក្ខខណ្ឌទូទៅនៃការងារ កិច្ចគាំពារសង្គម និងអត្ថប្រយោជន៍ផ្សេងៗរបស់ពលករ។

៧-ពិនិត្យលទ្ធភាពផ្លូវច្បាប់ និងរៀបចំបទដ្ឋានគតិយុត្តផ្សេងៗជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីឈានទៅដល់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករទេសន្តរប្រវេសន៍កម្ពុជាទៅធ្វើការនៅផ្នែកនេសាទ។

៨- សម្របសម្រួល និងសហការជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ា ឡាវ និងថៃ ដើម្បីរៀបចំឱ្យមានគម្រូបទដ្ឋានកិច្ចសន្យាការងារសម្រាប់ពលករធ្វើការក្នុងផ្នែកនេសាទក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO និងដៃគូផ្សេងៗទៀត។

៩- ពង្រឹងការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគី និងពហុភាគីតាមរយៈកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី។

### ៧.១.៣- គោលដៅ១.៣៖ ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន រាជរដ្ឋាភិបាលរៀបចំកែសម្រួលនូវបញ្ជីត្រួតពិនិត្យ នីតិវិធីអធិការកិច្ច ពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច សម្រាប់វាយតម្លៃដោយសុក្រឹត្យលើការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជន។

**វិធានការ៖**

១- ពិនិត្យ និងកែលម្អឡើងវិញនូវលក្ខខណ្ឌ កាតព្វកិច្ចរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលកំណត់នៅក្នុងកិច្ចសន្យារបស់ទីភ្នាក់ងារជ្រើសរើសឯកជន សម្រាប់ទទួលបានការអនុញ្ញាតឱ្យជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។

២- ធានាថាគ្រប់ម្ចាស់ ឬអ្នកគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន និងប្រធានមជ្ឈមណ្ឌលណែនាំតម្រង់ទិសត្រូវគោរពតាមលិខិតបទដ្ឋានគតិយុត្ត នៃការធ្វើទេសន្តរប្រវេសន៍ការងារ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល និងប្រឡងជាប់មុនពេលចុះកិច្ចសន្យា ដើម្បីទទួលបានការអនុញ្ញាត ហើយត្រូវធ្វើការប្រឡងឡើងវិញរៀងរាល់៣ឆ្នាំម្តង និងធ្វើការប្រកួតប្រជែងជ្រើសរើសចំណាត់ថ្នាក់ប្រសើរ ជារៀងរាល់ឆ្នាំ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

៣- បន្ត និងជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធអេឡិចត្រូនិចសម្រាប់ពលករទេសន្តរប្រវេសន៍ការងារនៅកម្ពុជា។

៤- បន្តពង្រឹងសមត្ថភាពសមាគម និងទីភ្នាក់ងារជ្រើសរើសឯកជនក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តក្រមប្រតិបត្តិ (Code of Conduct) និងសីលធម៌វិជ្ជាជីវៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការជ្រើសរើសពលករត្រឹមត្រូវប្រកបដោយក្រមសីលធម៌ ជាពិសេសពង្រឹងគុណភាពនៃការអប់រំណែនាំតម្រង់ទិសដល់ពលករមុនចេញទៅធ្វើការនៅបរទេស។

៥- បន្តពង្រឹងអធិការកិច្ចការងារ និងធ្វើបច្ចុប្បន្នភាពបញ្ជីត្រួតពិនិត្យ (Checklist) ទីភ្នាក់ងារជ្រើសរើសឯកជន និងបន្តចាត់វិធានការព្រមាន ព្យួរ ឬលុបចោលការអនុញ្ញាតរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងករណីរកឃើញកំហុសជាក់ស្តែងច្រើនដងដែលមិនអាចកែបាន។

៦- បន្តពង្រឹងការគ្រប់គ្រងលើការផ្សព្វផ្សាយរបស់ទីភ្នាក់ងារជ្រើសរើសឯកជន អំពីការជ្រើសរើសពលករទៅធ្វើការនៅបរទេស និងសមត្ថភាពទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការសម្របសម្រួល ដោះស្រាយបញ្ហានានាទាក់ទងនឹងលក្ខខណ្ឌការងារ លក្ខខណ្ឌរស់នៅ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។

៧- សម្របសម្រួល និងជំរុញឱ្យទីភ្នាក់ងារជ្រើសរើសឯកជន កំណត់តម្លៃសេវាបញ្ជូនពលករ ដោយមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ ស្របទៅតាមការអនុវត្តនៅក្នុងតំបន់។

៨- ជំរុញទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ ឬរួមគ្នាចាត់តំណាងអចិន្ត្រៃយ៍ទៅប្រចាំនៅប្រទេសគោលដៅ និងជួយពលករឱ្យបានចុះបញ្ជីនៅក្នុងរបបសន្តិសុខសង្គមនៃប្រទេសគោលដៅ។

### ៧.១.៤- គោលដៅ១.៤៖ បន្តកសាងសមត្ថភាពមន្ត្រី និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ និងពង្រឹកកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ការកសាងសមត្ថភាពមន្ត្រី និងពង្រឹកកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាការចាំបាច់ក្នុងការពង្រឹងយន្តការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារឱ្យកាន់តែមានប្រសិទ្ធភាព។

**វិធានការ៖**

១- រៀបចំការបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារដល់ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទីភ្នាក់ងារជ្រើសរើសឯកជន សហជីព សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

២- បង្កើនសមត្ថភាពមន្ត្រីជំនាញ និងភាគីពាក់ព័ន្ធលើការគ្រប់គ្រង ការផ្តល់សេវាគាំទ្រ និងការដោះស្រាយវិវាទទេសន្តរប្រវេសន៍ការងារតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងអន្តរជាតិ។

៣- បង្កើនច្រកចេញចូលតែមួយនៅតាមបណ្តាខេត្តគោលដៅក្នុងករណីចាំបាច់ ដើម្បីរៀបចំ និងផ្តល់ឯកសារ លិខិតស្នាមនានាដល់ពលករទេសន្តរប្រវេសន៍។

៤- បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៃក្រុមការងារទេសន្តរប្រវេសន៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥- ប្រមូលកៀរគរធនធានបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីកសាងសមត្ថភាពមន្ត្រី និងភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារ។

### ៧.១.៥- គោលដៅ១.៥៖ ប្រមូល ចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍

ការប្រមូល ចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ មានសារៈសំខាន់សម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្តនានា។

**វិធានការ៖**

១-ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។

២- សិក្សាប្រមូលចងក្រងអំពីឧត្តមានុវត្ត បទពិសោធន៍ និងបញ្ហាប្រឈម សម្រាប់ធ្វើជាធាតុចូលក្នុងការដោះស្រាយបញ្ហារបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសក្រុមជនទេសន្តរប្រវេសន៍

ដែលងាយរងគ្រោះ។

៣-ពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់គ្រប់គ្រងទេសន្តរប្រវេសន៍ការងារ។

៤-បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

### ៧.១.៦- គោលដៅ១.៦៖ បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

មណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) នឹងត្រូវបានបង្កើតឡើងជាផ្លូវការ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្សព្វផ្សាយ អំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព និងចូលរួមទប់ស្កាត់ការធ្វើទេសន្តរប្រវេសន៍ការងារប្រថុយប្រថាននិងប្រកបដោយគ្រោះថ្នាក់។

**វិធានការ៖**

១- សិក្សាវាយតម្លៃការអនុវត្តសាកល្បងលើគម្រោងមណ្ឌលធនធានពលករទេសន្តរប្រវេសន៍របស់អង្គការILO និងអង្គការ IOM ដើម្បីប្រែក្លាយមណ្ឌលនេះ ទៅជារចនាសម្ព័ន្ធផ្លូវការរបស់អគ្គនាយកដ្ឋានការងារ/ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២- សិក្សាលទ្ធភាព បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍នៅក្រៅប្រទេស ដើម្បីជួយគាំទ្របន្ថែមដល់ស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារក្នុងការផ្តល់ព័ត៌មាន សេវាច្បាប់ និងការងារមនុស្សធម៌ដល់ពលករទេសន្តរប្រវេសន៍នៅតាមប្រទេសទទួល។

៣- ស្វែងរកការគាំទ្រពីភាគីពាក់ព័ន្ធ ក្នុងការទ្រទ្រង់មណ្ឌលធនធានពលករទេសន្តរប្រវេសន៍នៅក្នុង និងក្រៅប្រទេស។

## ៧.២- គោលបំណងទី២៖ ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការការពារពលករទេសន្តរប្រវេសន៍ តាមរយៈការផ្តល់ការអប់រំណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរ ការចេញគោលការណ៍ណែនាំស្តីពីការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍ និងការធានាឱ្យពលករទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម។

### ៧.២.១- គោលដៅ២.១៖ ពង្រឹង និងពង្រីកសេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុលនៅបណ្តាប្រទេសទទួល

សេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថាន កុងស៊ុលត្រូវបានពង្រឹង និងពង្រីកក្នុងបណ្តាប្រទេសទទួល ដើម្បីផ្តល់ជំនួយ ឬកិច្ចអន្តរាគមន៍នានាដល់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះផ្សេងទៀតឱ្យកាន់តែមានប្រសិទ្ធភាព ដោយមិនគិតអំពីស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់របស់ពួកគេឡើយ។

**វិធានការ៖**

១-បន្តរៀបចំឱ្យមានទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុលនៅគ្រប់បណ្តាប្រទេសទទួល។

២-ពង្រឹងសមត្ថភាពទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា។

៣-សម្របសម្រួលផ្តល់សេវាច្បាប់ ដល់ពលករពេលមានវិវាទការងារ និងពេលទាមទារអត្ថប្រយោជន៍ផ្សេងៗ ដោះស្រាយវិវាទការងារ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសន៍នៅពេលចប់កិច្ចសន្យាការងារ ក៏ដូចជាសម្របសម្រួលការបញ្ជូនអដ្ឋិធាតុ ឬសព ក្នុងករណីមានពលករទទួលមរណភាពដោយថាហេតុ។

៤-ចុះស្វែងយល់ផ្ទាល់អំពីការរស់នៅ និងលក្ខខណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍ ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងអ្នកផ្តល់សេវានានានៅតាមប្រទេសទទួល ដើម្បីផ្តល់សេវាគាំទ្រ ឱកាសការងារ សេវាបកប្រែភាសា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការសន្សំប្រាក់ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។

៥-សិក្សាស្រាវជ្រាវ និងចរចាជាមួយប្រទេសទទួល ដើម្បីពង្រីកទីផ្សារការងារ និងពង្រឹងការការពារសិទ្ធិពលករ។

៦-ធ្វើអន្តរាគមន៍ ឬសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ក្នុងករណីមានប្រធានសក្តិកើតឡើងនៅប្រទេសទទួល។

### ៧.២.២- គោលដៅ២.២៖ ពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងពលករទេសន្តរប្រវេសន៍

ការពង្រឹងការទទួលបានសេវាយុត្តិធម៌ដល់ពលករទេសន្តរប្រវេសន៍ ត្រូវបានធ្វើឡើងតាមរយៈយន្តការទទួល និងដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងគិតគូរពីយេនឌ័រ។

**វិធានការ៖**

១-បន្តផ្សះផ្សាវិវាទទាក់ទងនឹងពលករទេសន្តរប្រវេសន៍ឱ្យបានសមស្រប ទាន់ពេលវេលា និងប្រកបដោយតម្លាភាព។

២- រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់ដោះស្រាយវិវាទ របស់ពលករទេសន្តរប្រវេសន៍។

៣- ផ្តល់ការគាំទ្រប្រឹក្សាយោបល់ និងជំនួយផ្លូវច្បាប់ដល់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះនៅពេលពួកគេដាក់ពាក្យបណ្តឹង ឬចូលរួមក្នុងនីតិវិធី និងដំណើរការតាមប្រព័ន្ធតុលាការ។

៤- ផ្តល់ការបណ្តុះបណ្តាលកសាងសមត្ថភាពដល់អ្នកផ្តល់ប្រឹក្សាយោបល់ និងអ្នកធ្វើការងារពាក់ព័ន្ធ។

### ៧.២.៣- គោលដៅ២.៣៖ ចងក្រង ផលិត បោះពុម្ពឯកសារ និងផ្សព្វផ្សាយអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពឱ្យបានទូលំទូលាយ

ឯកសារ និងព័ត៌មានស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព និងសិទ្ធិនៅកន្លែងធ្វើការ ត្រូវបានចងក្រង ផលិត បោះពុម្ព និងផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋ ជាពិសេសអ្នកនៅតាមសហគមន៍មូលដ្ឋាន។

**វិធានការ៖**

១- រៀបចំចងក្រង និងផលិតឯកសារ និងព័ត៌មានស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព និងសិទ្ធិនៅកន្លែងធ្វើការ។

២- ផ្សព្វផ្សាយ និងចែកខិត្តបណ្ណព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។

៣- ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈដោយផ្តោតលើចំណេះដឹង ជំនាញថ្មីៗ និងបទពិសោធន៍ជោគជ័យរបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសស្ត្រី ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

៤- ផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារការងារ និងឱកាសការងារក្រៅប្រទេសដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេសយុវជន និងអ្នកដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ។

៥- សហការជាមួយអង្គការ ILO អង្គការ IOM សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងអ្នកជំនាញផ្សេងៗ បង្កើតកម្មវិធីផ្សព្វផ្សាយពីអត្ថប្រយោជន៍ ឬភាពជោគជ័យនៃការធ្វើទេសន្តរប្រវេសន៍ការងារ ចំពោះពលករ ក្រុមគ្រួសារពលករ និងសហគមន៍។

### ៧.២.៤- គោលដៅ២.៤៖ ពង្រឹង និងពង្រីកយន្តការផ្តល់អត្ថប្រយោជន៍ នៃកម្មវិធីកិច្ចគាំពារសង្គមដល់ពលករទេសន្តរប្រវេសន៍

អត្ថប្រយោជន៍ ដែលទទួលបានពីកម្មវិធីកិច្ចគាំពារសង្គម មានតួនាទីយ៉ាងសំខាន់ក្នុងការការពារពលករទេសន្តរប្រវេសន៍នៅពេលជួបប្រទះនូវបញ្ហា ឬបាត់បង់លទ្ធភាពក្នុងការធ្វើការងារ និងរកប្រាក់ចំណូល ដើម្បីជួយរក្សាលំនឹងជីវភាពរបស់ពួកគេ។ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ ចំពោះពលករទេសន្តរប្រវេសន៍កម្ពុជាគ្រប់រូបឱ្យទទួលបានអត្ថប្រយោជន៍ពីកម្មវិធីកិច្ចគាំពារសង្គម។

**វិធានការ៖**

១- គាំទ្រការពង្រីកសេវារបស់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ទាំងអស់។

២- រៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគី ឬពហុភាគីរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីសិក្សាអំពីទិដ្ឋភាពច្បាប់ និងនីតិវិធីក្នុងការធានាឱ្យពលករទេសន្តរប្រវេសន៍ទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍ពីកម្មវិធីកិច្ចគាំពារសង្គម។

៣- ពន្លឿនការចរចាជាមួយនឹងប្រទេសទទួល ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមដើម្បីបង្កលក្ខណៈសម្បត្តិឱ្យពលករទទួលបានរបបគាំពារសង្គមទាំងក្នុងពេលធ្វើការ និងពេលដែលវិលត្រឡប់មកមាតុប្រទេសវិញ។

## ៧.៣- គោលបំណងទី៣៖ ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកថាការធ្វើទេសន្តរប្រវេសន៍ការងារ ជាចលករមួយដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងទទួលស្គាល់ថាពលករទេសន្តរប្រវេសន៍ជាភ្នាក់ងារនៃការច្នៃប្រឌិតថ្មី និងការអភិវឌ្ឍ។ ជាមួយគ្នានេះ ការធ្វើទេសន្តរប្រវេសន៍ការងារទៅក្រៅប្រទេស គឺជាឱកាស និងជម្រើសការងារបន្ថែមដោយពលករទេសន្តរប្រវេសន៍ មិនត្រឹមតែទទួលបានប្រាក់ឈ្នួលសមរម្យប៉ុណ្ណោះទេ ប៉ុន្តែក៏ទទួលបានជំនាញ ចំណេះដឹង ធនធាន និងបទពិសោធន៍ផងដែរ។

### ៧.៣.១- គោលដៅ៣.១ ៖ លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍

ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធធនាគារ និងការផ្ញើប្រាក់របស់ពលករទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ ទាមទារឱ្យមានកិច្ចសហការរវាងស្ថាប័នហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និងប្រទេសគោលដៅ ព្រមទាំងការផ្តល់សេវាគាំទ្រនានាក្នុងការវិនិយោគ និងការសន្សំប្រាក់ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។

**វិធានការ៖**

១-ជំរុញទីភ្នាក់ងារជ្រើសរើសឯកជនជួយសម្របសម្រួលដល់ពលករទេសន្តរប្រវេសន៍ ក្នុងការបង្កើតគណនីធនាគារ ដើម្បីងាយស្រួលទទួលប្រាក់ឈ្នួល ឬប្រាក់អត្ថប្រយោជន៍ផ្សេងៗ និងផ្ញើប្រាក់តាមប្រព័ន្ធធនាគារនៅតាមប្រទេសគោលដៅ។

២-លើកទឹកចិត្តគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការផ្តល់សេវាផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍ពីប្រទេសទទួលឱ្យកាន់តែទូលំទូលាយ។

៣- ជំរុញពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារ។

៤- សិក្សាអំពីការអនុវត្តការផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍ពីបណ្តាប្រទេសផ្សេងៗ ដើម្បីបង្កើនការយល់ដឹងអំពីសេវាផ្ញើប្រាក់ និងការចំណាយលើសេវាផ្ញើប្រាក់។

### ៧.៣.២- គោលដៅ៣.២៖ ពង្រឹងយន្តការគាំទ្រគ្រួសារពលករ និងយន្តការសមាហរណកម្មពលករទេសន្តរប្រវេសន៍ក្នុងសហគមន៍

ការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាព សម្រាប់ពលករទេសន្តរប្រវេសន៍ត្រូវបានលើកកម្ពស់កាន់តែប្រសើរ តាមរយៈការដាក់ចេញនូវវិធានការ ដោយផ្អែកលើស្ថានភាពជាក់ស្តែង និងការពង្រឹងសេវាគាំទ្រនានាសម្រាប់ការធ្វើសមាហរណកម្ម។

**វិធានការៈ**

១- សហការជាមួយទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ ក្នុងការធ្វើមាតុភូមិនិវត្តន៍របស់ពលករឱ្យមានសុវត្ថិភាព និងទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ស្របតាមការកំណត់ដោយច្បាប់របស់ប្រទេសទទួល។

២- ផ្តល់សេវាគាំទ្រ និងប្រឹក្សាយោបល់ដល់ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ អំពីវប្បធម៌ ការគ្រប់គ្រងអារម្មណ៍ផ្លូវកាយ និងផ្លូវចិត្ត ពាក់ព័ន្ធជាមួយនឹងទីតាំងភូមិសាស្ត្រស្រុកកំណើតរបស់ពលករ មុនពេលធ្វើសមាហរណកម្មក្នុងគ្រួសារ និងសហគមន៍។

៣- សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ ទីភ្នាក់ងារជ្រើសរើសឯកជន និងសហគមន៍ពលករ ចងក្រងទិន្នន័យ និងចុះឈ្មោះពលករដែលចប់កិច្ចសន្យាការងារ ទៅក្នុងទិន្នន័យរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ឱកាសការងារ និងសេវារកការងារឱ្យធ្វើក្នុងស្រុក និងក្រៅស្រុក។

៤- រៀបចំយន្តការផ្តល់សេវាគាំទ្រដល់គ្រួសាររបស់ពលករ ក្នុងការប្រាស្រ័យទាក់ទងជាមួយពលករ សេវាទទួលប្រាក់បញ្ញើ និងលទ្ធភាពបង្កើតជាសហគមន៍គ្រួសារពលករដើម្បីចែករំលែកនូវព័ត៌មាន និងបទពិសោធន៍។

៥- ផ្តល់ការបណ្តុះបណ្តាលចំណេះដឹងផ្នែកសហគ្រិនភាព និងហិរញ្ញវត្ថុ ជាពិសេសការប្រើប្រាស់ប្រាក់បញ្ញើឱ្យទទួលបានផលប្រយោជន៍ខ្ពស់ និងសេវាប្រឹក្សាយោបល់ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងការប្រកបអាជីវកម្ម និងការវិនិយោគផ្សេងៗ។

### ៧.៣.៣- គោលដៅ៣.៣៖ ពង្រីកទីផ្សារការងារដែលមានជំនាញលើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មុនពេលចេញដំណើរ និងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍

ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍ ជាស្ត្រី បុរស និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះផ្សេងទៀត ត្រូវបានលើកកម្ពស់ ដើម្បីទទួលបានការងារសមរម្យ និងបង្កើនប្រាក់ចំណូល។

**វិធានការៈ**

១- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យម លើភាសា ជំនាញវិជ្ជាជីវៈ និងសុខភាព និងសុវត្ថិភាពការងារ ដើម្បីបង្កើនសមត្ថភាពរបស់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ។

២- ពិគ្រោះយោបល់ជាមួយតំណាងរដ្ឋាភិបាល និងនិយោជកនៃប្រទេសទទួល អំពីតម្រូវការទីផ្សារការងារ ជំនាញវិជ្ជាជីវៈ និងវិស័យជាក់លាក់នីមួយៗ ជាពិសេសការទទួលស្គាល់ជំនាញ។

៣- បន្តសម្របសម្រួលជាមួយរដ្ឋសមាជិកអាស៊ានផ្សេងទៀត ដើម្បីបង្កើតស្តង់ដាររួមនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្នុងក្របខណ្ឌអាស៊ានសម្រាប់ពលករទេសន្តរប្រវេសន៍។

៤- លើកកម្ពស់ការទទួលស្គាល់ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ជំនាញ និងគុណវុឌ្ឍិសម្រាប់

ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះនៅប្រទេសគោលដៅ។

៥- ជំរុញការទទួលស្គាល់ជំនាញ ដោយធ្វើការវាយតម្លៃជំនាញ ដែលបានទទួលការបណ្តុះបណ្តាលស្តង់ដាសមត្ថភាព និងការចេញវិញ្ញាបនបត្របញ្ជាក់ជំនាញដល់ពលករទេសន្តរប្រវេសន៍ បន្ទាប់ពីពួកគេបានធ្វើមាតុភូមិនិវត្តន៍។

## ៨- ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងប្រភពហិរញ្ញវត្ថុ

ដើម្បីធានាវឌ្ឍនភាព ប្រសិទ្ធភាព និងសង្គតិភាពជាប្រចាំក្នុងការអនុវត្តគោលនយោបាយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាស្ថាប័នទទួលបន្ទុកក្នុងការសម្របសម្រួល តាមដានត្រួតពិនិត្យ និង វាយតម្លៃលើការអនុវត្ត **គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣** ដោយបង្កើតគណៈកម្មការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងមានលេខាធិការដ្ឋានមួយសម្រាប់សម្របសម្រួលដំណើរការអនុវត្តគោននយោបាយនេះ។

គណៈកម្មការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នឹងរៀបចំសូចនាករ និងរបាយការណ៍ ដែលអាចវាស់វែងបាន ស្របទៅតាមផែនការសកម្មភាពនៅក្នុងតារាងម៉ាទ្រីកនៃគោលនយោបាយនេះ ដើម្បីជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ។

ប្រភពហិរញ្ញវត្ថុសម្រាប់អនុវត្តគោលនយោបាយនេះ រួមមានថវិកាជាតិ និងថវិការបស់អង្គការ ILO ដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា។

## ៩- សេចក្តីសន្និដ្ឋាន

ឯកសារ **"គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣"** ត្រូវបានរៀបចំឡើងដោយមានជំនួយបច្ចេកទេសរបស់អង្គការ ILO និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមនិយោជក សមាគមទីភ្នាក់ងារជ្រើសរើសឯកជន សហជីពកម្មករនិយោជិត អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា និងដោយផ្អែកលើសមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមនៃការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍សម្រាប់ប្រទេសកម្ពុជា ទាំងពីរជំណាក់កាលកន្លងមក (លើកទី១នៅឆ្នាំ២០១០-២០១៤ និងលើកទី២នៅឆ្នាំ២០១៥-២០១៨)។ គោលនយោបាយនេះ បានដាក់ចេញនូវកញ្ចប់វិធានការ ដែលកាន់តែគ្រប់ជ្រុងជ្រោយ និងជាក់ស្តែង ដែលអាចអនុវត្តបានដើម្បីធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការសម្រេចឱ្យបាននូវគោលបំណងទាំង៣ គឺ (១) **ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ (២) ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និង (៣) ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។**

ការដាក់ឱ្យអនុវត្តគោលនយោបាយនេះ បានបង្ហាញអំពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការការពារ លើកកម្ពស់សិទ្ធិ និងលក្ខខណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍ ក៏ដូចជាពង្រឹងយន្តការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយប្រសិទ្ធភាព សំដៅធានាឱ្យបាននូវផលប្រយោជន៍វិជ្ជមានជាអតិបរមាដល់ពលករ ក្រុមគ្រួសារ ក៏ដូចជាសង្គមជាតិ។

# ឧបសម្ព័ន្ធ១ ៖ គំនូសបំព្រួញក្របខ័ណ្ឌនៃគោលនយោបាយ

## គោលនយោបាយ ស្តីពី ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣

**ចក្ខុវិស័យនៃគោលនយោបាយ**

ដើម្បីពង្រឹងយន្តការគ្រប់គ្រង ការពារ និងលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព សំដៅធានាការទទួលបានឱកាសការងារសមរម្យ ការអភិវឌ្ឍជំនាញចំណេះដឹង បទពិសោធន៍ធនធាន និងអត្ថប្រយោជន៍នៃកិច្ចគាំពារសង្គមដល់ពលករ សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

### គោលបំណងទី១
ការពង្រឹង អភិបាលកិច្ច ទេសន្តរប្រវេសន៍ការងារ

**គោលដៅ**

១. ធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ
២. ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីនិងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ
៣. ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន
៤. បន្តកសាងសមត្ថភាពមន្ត្រី និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ និងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
៥. ប្រមូល ចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធ នឹងពលករទេសន្តរប្រវេសន៍
៦. បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(Migrant Resources Center - MRC) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### គោលបំណងទី២
ការការពារនិង លើកកម្ពស់សិទ្ធិ ពលករទេសន្តរប្រវេសន៍

**គោលដៅ**

១. ពង្រឹង និងពង្រីកសេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល នៅបណ្តាប្រទេសទទួល
២. ពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងពលករទេសន្តរប្រវេសន៍
៣. ចងក្រង ផលិត បោះពុម្ពឯកសារ និងផ្សព្វផ្សាយអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពឱ្យបានទូលំទូលាយ
៤. ពង្រឹង និងពង្រីកយន្តការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីកិច្ចគាំពារសង្គមដល់ពលករទេសន្តរប្រវេសន៍

### គោលបំណងទី៣
ការផ្សារភ្ជាប់ ទេសន្តរប្រវេសន៍ ការងារទៅនឹងការ អភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

**គោលដៅ**

១. លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍
២. ពង្រឹងយន្តការគាំទ្រគ្រួសារពលករ និងយន្តការសមាហរណកម្មពលករទេសន្តរប្រវេសន៍ក្នុងសហគមន៍
៣. ពង្រីកទីផ្សារការងារដែលមានជំនាញលើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មុនពេលចេញដំណើរនិងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍

## ឧបសម្ព័ន្ធ២ ៖ តារាងម៉ាទ្រីកនៃគោលនយោបាយ គោលបំណង គោលដៅ និងផែនការសកម្មភាព

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| **គោលបំណងទី១៖ ការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ** | | | | |
| **គោលដៅ១.១៖ ធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ** | ១- កសាងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារនៅបរទេស។ | ២០១៩-២០២១ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- បង្កើនការយល់ដឹង និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនានាអំពីបទដ្ឋានជាតិនិងអន្តរជាតិទាក់ទងនឹងទេសន្តរប្រវេសន៍ការងារ ជាពិសេសឯកច្ឆ័ន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ព្រមទាំងឧត្តមានុវត្ត នៅថ្នាក់តំបន់ ឬអន្តរជាតិ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ពង្រឹងការអនុវត្តបទប្បញ្ញត្តិ និងសិក្សាពីលទ្ធភាពក្នុងការផ្តល់សច្ចាប័នលើបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធនានាដូចជា អនុសញ្ញាអន្តរជាតិខាងការងារលេខ៩៧, លេខ១៤៣, លេខ១៨១ លេខ១៨៨, លេខ១៨៩, ពិធីសារស្តីពីការងារដោយបង្ខំ និងអនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ពលករទេសន្តរប្រវេសន៍គ្រប់រូបនិងសមាជិកគ្រួសាររបស់ពួកគេ ដោយស្របតាមបរិបទកម្ពុជា។ | | | |
| | ៤- លើកកម្រិតគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ឱ្យទៅជាគោលនយោបាយថ្នាក់ជាតិ។ | ២០២១-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ |
| **គោលដៅ១.២៖ ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ** | ១- រៀបចំកិច្ចពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- ចូលរួមកិច្ចពិគ្រោះយោបល់នៅថ្នាក់តំបន់ និងរៀបចំលិខិតូបករណ៍ពាក់ព័ន្ធនឹងការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ ដូចជាការចូលរួម និងផ្តល់អនុសាសន៍ក្នុងវេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ចូលរួមសហការពង្រឹងប្រព័ន្ធគ្រប់គ្រងស្ថិតិទេសន្តរប្រវេសន៍ការងារអាស៊ាន និងធ្វើការវិភាគទិន្នន័យដែលប្រមូលបាន ដើម្បីប្រើប្រាស់សម្រាប់ការរៀបចំគោលនយោបាយនានា។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៤- បន្តកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសបញ្ជូន ដើម្បីពង្រឹងតួនាទី និងការអនុវត្តល្អៗលើអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៥- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងដៃគូអភិវឌ្ឍន៍ អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដើម្បីធ្វើការចែករំលែកបទពិសោធន៍ និងសកម្មភាពការងារ ចៀសវាងការអនុវត្តសកម្មភាពត្រួតគ្នា និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៦-ចុះកិច្ចព្រមព្រៀង/អនុស្សរណៈនៃការយោគយល់គ្នា (MOU) លើកិច្ចសហប្រតិបត្តិការទេសន្តរប្រវេសន៍ការងារជាមួយបណ្តាប្រទេសនានា ដោយផ្តោតលើលក្ខខណ្ឌទូទៅនៃការងារ កិច្ចគាំពារសង្គម និងអត្ថប្រយោជន៍ផ្សេងៗរបស់ពលករ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៧- ពិនិត្យលទ្ធភាពផ្លូវច្បាប់ និងរៀបចំបទដ្ឋានគតិយុត្តផ្សេងៗជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីឈានទៅដល់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករទេសន្តរប្រវេសន៍កម្ពុជាទៅធ្វើការនៅផ្នែកនេសាទ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៨- សម្របសម្រួល និងសហការជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ាឡារ និងថៃ ដើម្បីរៀបចំឱ្យមានគម្រូបទដ្ឋានកិច្ចសន្យាការងារសម្រាប់ពលករធ្វើការក្នុងផ្នែកនេសាទក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO និងដៃគូ ផ្សេងៗទៀត។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៩- ពង្រឹងការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាទ្វេភាគី និងពហុភាគី តាមរយៈកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងសមាគមទីភ្នាក់ងារជ្រើសរើសពលករ |
| **គោលដៅ១.៣៖ ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន** | ១- ពិនិត្យ និងកែលម្អឡើងវិញនូវលក្ខខណ្ឌ កាតព្វកិច្ចរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលកំណត់នៅក្នុងកិច្ចសន្យារបស់ទីភ្នាក់ងារជ្រើសរើសឯកជន សម្រាប់ទទួលបានការអនុញ្ញាតឱ្យជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។ | ២០២១-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- ធានាថាគ្រប់ម្ចាស់ ឬអ្នកគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន និងប្រធានមជ្ឈមណ្ឌលណែនាំតម្រង់ទិសត្រូវគោរពតាមលិខិតបទដ្ឋានគតិយុត្ត នៃការធ្វើទេសន្តរប្រវេសន៍ការងារ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល និងប្រឡងជាប់មុនពេលចុះកិច្ចសន្យា ដើម្បីទទួលបានការអនុញ្ញាត ហើយត្រូវធ្វើការប្រឡងឡើងវិញរៀងរាល់៣ឆ្នាំម្តង និងធ្វើការ | ២០២១-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ប្រកួតប្រជែងជ្រើសរើសចំណាត់ថ្នាក់ប្រសើរ ជារៀងរាល់ឆ្នាំ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | | | |
| | ៣- បន្ត និងជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធអេឡិចត្រូនិចសម្រាប់ពលករទេសន្តរប្រវេសន៍ការងារនៅកម្ពុជា។ | ២០២១-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤- បន្តពង្រឹងសមត្ថភាពសមាគម និងទីភ្នាក់ងារជ្រើសរើសឯកជនក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តក្រមប្រតិបត្តិ (Code of Conduct) និងសីលធម៌វិជ្ជាជីវៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការជ្រើសរើសពលករត្រឹមត្រូវប្រកបដោយក្រមសីលធម៌ជាពិសេសពង្រឹងគុណភាពនៃការអប់រំណែនាំតម្រង់ទិសដល់ពលករមុនចេញទៅធ្វើការនៅបរទេស។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៥- បន្តពង្រឹងអធិការកិច្ចការងារ និងធ្វើបច្ចុប្បន្នភាពបញ្ជីត្រួតពិនិត្យ (Checklist) ទីភ្នាក់ងារជ្រើសរើសឯកជន និងបន្តចាត់វិធានការព្រមាន ព្យួរ ឬលុបចោលការអនុញ្ញាតរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងករណីរកឃើញកំហុសជាក់ស្តែងច្រើនដងដែលមិនអាចកែបាន។ | ២០១៩-២០២១ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៦-បន្តពង្រឹងការគ្រប់គ្រងលើការផ្សព្វផ្សាយរបស់ទីភ្នាក់ងារជ្រើសរើសឯកជនអំពីការជ្រើសរើសពលករទៅធ្វើការនៅបរទេស និងសមត្ថភាពទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងការសម្របសម្រួល ដោះស្រាយបញ្ហានានាទាក់ទងនឹងលក្ខខណ្ឌការងារ លក្ខខណ្ឌរស់នៅនិងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងព័ត៌មាន | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៧- សម្របសម្រួល និងជំរុញឱ្យភ្នាក់ងារជ្រើសរើសឯកជនកំណត់តម្លៃសេវាបញ្ជូនពលករដោយមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ ស្របទៅតាមការអនុវត្តនៅក្នុងតំបន់។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៨- ជំរុញទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ ឬរួមគ្នាចាត់តំណាងអចិន្ត្រៃយ៍ទៅប្រចាំនៅប្រទេសគោលដៅ និងជួយពលករឱ្យបានចុះបញ្ជីនៅក្នុងរបបសន្តិសុខសង្គមនៃប្រទេសគោលដៅ។ | ២០២១-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- បេឡាជាតិសន្តិសុខសង្គម | អង្គការ ILO, អង្គការ IOM, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| **គោលដៅ១.៤៖ បន្តកសាងសមត្ថភាពមន្ត្រី និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារនិងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** | ១- រៀបចំការបណ្តុះបណ្តាលអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារដល់ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទីភ្នាក់ងារជ្រើសរើសឯកជន សហជីព សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀត។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២-បង្កើនសមត្ថភាពមន្ត្រីជំនាញ និងភាគីពាក់ព័ន្ធលើការគ្រប់គ្រង ការផ្តល់សេវាគាំទ្រ និងការដោះស្រាយវិវាទទេសន្តរប្រវេសន៍ការងារតាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងអន្តរជាតិ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- បង្កើនច្រកចេញចូលតែមួយនៅតាមបណ្តាខេត្តគោលដៅក្នុងករណីចាំបាច់ ដើម្បីរៀបចំ និងផ្តល់ឯកសារលិខិតស្នាមនានាដល់ពលករទេសន្តរប្រវេសន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងមហាផ្ទៃ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤- បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៃក្រុមការងារទេសន្តរប្រវេសន៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៥- ប្រមូលកៀរគរធនធានបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីកសាងសមត្ថភាពមន្ត្រី និងភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលដៅ១.៥៖ ប្រមូលចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍** | ១- ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- សិក្សាប្រមូលចងក្រងអំពីឧត្តមានុវត្ត បទពិសោធន៍ និងបញ្ហាប្រឈមសម្រាប់ធ្វើជាធាតុចូលក្នុងការដោះស្រាយបញ្ហារបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់គ្រប់គ្រងទេសន្តរប្រវេសន៍ការងារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៤- បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។ | ២០១៩-២០២១ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលដៅ១.៦៖ បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ (MRC) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | ១- សិក្សាវាយតម្លៃការអនុវត្តសាកល្បងលើគម្រោងមណ្ឌលធនធានពលករទេសន្តរប្រវេសន៍របស់អង្គការ ILO និង អង្គការ IOM ដើម្បីប្រែក្លាយមណ្ឌលនេះ ទៅជារចនាសម្ព័ន្ធផ្លូវការរបស់អគ្គនាយកដ្ឋានការងារ/ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ២០១៩-២០២១ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, និង សមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- សិក្សាលទ្ធភាព បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍នៅក្រៅប្រទេស ដើម្បីជួយគាំទ្របន្ថែមដល់ស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារក្នុងការផ្តល់ព័ត៌មាន សេវាច្បាប់ និងការងារមនុស្សធម៌ដល់ពលករទេសន្តរប្រវេសន៍នៅតាមប្រទេសទទួល។ | ២០២១-២០២៣ | - ក្រុមការងារគ្រប់គ្រងពលករខ្មែរធ្វើការនៅបរទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងភាគីពាក់ព័ន្ធ |
| | ៣-ស្វែងរកការគាំទ្រពីភាគីពាក់ព័ន្ធ ក្នុងការទ្រទ្រង់មណ្ឌលធនធានពលករទេសន្តរប្រវេសន៍នៅក្នុង និងក្រៅប្រទេស។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជននិងភាគីពាក់ព័ន្ធ |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| គោលបំណងទី២៖ ការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ | | | | |
| គោលដៅ២.១៖ ពង្រឹង និងពង្រីកសេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុលនៅបណ្តាប្រទេសទទួល | ១-បន្តរៀបចំឱ្យមានទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុលនៅគ្រប់បណ្តាប្រទេសទទួល។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| | ២- ពង្រឹងសមត្ថភាពទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO |
| | ៣- សម្របសម្រួលផ្តល់សេវាច្បាប់ដល់ពលករពេលមានវិវាទការងារ និងពេលទាមទារអត្ថប្រយោជន៍ផ្សេងៗ ដោះស្រាយវិវាទការងារ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករទេសន្តរប្រវេសន៍នៅពេលចប់កិច្ចសន្យាការងារ ក៏ដូចជាសម្របសម្រួលការបញ្ជូនអដ្ឋិធាតុ ឬសព ក្នុងករណីមានពលករទទួលមរណភាពជាយថាហេតុ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងភាគីពាក់ព័ន្ធ |
| | ៤- ចុះស្វែងយល់ផ្ទាល់អំពីការរស់នៅ និងលក្ខខណ្ឌការងាររបស់ពលករទេសន្តរប្រវេសន៍ ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងអ្នកផ្តល់សេវានានានៅតាមប្រទេសទទួល ដើម្បីផ្តល់សេវាគាំទ្រ ឱកាសការងារ សេវា | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និងគោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
| --- | --- | --- | --- | --- |
| | បកប្រែភាសា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការសន្សំប្រាក់ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។ | | - ក្រសួង ស្ថាប័នពាក់ព័ន្ធ | |
| | ៥- សិក្សាស្រាវជ្រាវ និងចរចាជាមួយប្រទេសទទួល ដើម្បីពង្រីកទីផ្សារការងារ និងពង្រឹងការការពារសិទ្ធពលករ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងភាគីពាក់ព័ន្ធ |
| | ៦- ធ្វើអន្តរាគមន៍ ឬសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ក្នុងករណីមានប្រធានសក្តិកើតឡើងនៅប្រទេសទទួល។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល,សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលដៅ២.២៖ ពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងពលករទេសន្តរប្រវេសន៍** | ១-បន្តផ្សះផ្សាវិវាទទាក់ទងនឹងពលករទេសន្តរប្រវេសន៍ឱ្យបានសមស្រប ទាន់ពេលវេលា និងប្រកបដោយតម្លាភាព។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ២- រៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់ដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ផ្តល់ការគាំទ្រប្រឹក្សាយោបល់ និងជំនួយផ្លូវច្បាប់ដល់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះនៅពេលពួកគេដាក់ពាក្យបណ្តឹង ឬចូលរួមក្នុងនីតិវិធី និងដំណើរការតាមប្រព័ន្ធតុលាការ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤- ផ្តល់ការបណ្តុះបណ្តាលកសាងសមត្ថភាពដល់អ្នកផ្តល់ប្រឹក្សាយោបល់ និងអ្នកធ្វើការងារពាក់ព័ន្ធ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលដៅ២.៣៖ ចងក្រងផលិត បោះពុម្ពឯកសារ និងផ្សព្វផ្សាយអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកប** | ១- រៀបចំចងក្រង និងផលិតឯកសារ និងព័ត៌មានស្តីពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព និងសិទ្ធិនៅកន្លែងធ្វើការ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| **ដោយសុវត្ថិភាពឱ្យបានទូលំទូលាយ** | ២- ផ្សព្វផ្សាយ និងចែកចិត្តបណ្ណព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈដោយផ្តោតលើចំណេះដឹង ជំនាញថ្មីៗ និងបទពិសោធន៍ជោគជ័យរបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសស្ត្រី ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងព័ត៌មាន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤-ផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារការងារ និងឱកាសការងារក្រៅប្រទេសដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ជាពិសេសយុវជន និងអ្នកដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងព័ត៌មាន<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៥- សហការជាមួយអង្គការ ILO អង្គការ IOM សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងអ្នកជំនាញផ្សេងៗ បង្កើតកម្មវិធីផ្សព្វផ្សាយពីអត្ថប្រយោជន៍ ឬភាពជោគជ័យនៃការធ្វើទេសន្តរប្រវេសន៍ការងារចំពោះពលករ ក្រុមគ្រួសារពលករនិងសហគមន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| គោលដៅ២.៤៖ ពង្រឹង និងពង្រីកយន្តការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីកិច្ចគាំពារសង្គមដល់ពលករទេសន្តរប្រវេសន៍ | ១- គាំទ្រការពង្រីកសេវារបស់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ ពលករទេសន្តរប្រវេសន៍ទាំងអស់។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បេឡាជាតិសន្តិសុខសង្គម | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- រៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគី ឬពហុភាគីរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីសិក្សាអំពីទិដ្ឋភាពច្បាប់ និងនីតិវិធីក្នុងការធានាឱ្យពលករទេសន្តរប្រវេសន៍ទទួលបានរបបសន្តិសុខសង្គម និងអត្ថប្រយោជន៍ពីកម្មវិធីកិច្ចគាំពារសង្គម។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- បេឡាជាតិសន្តិសុខសង្គម<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ពន្លឿនការចរចាជាមួយនឹងប្រទេសទទួល ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមដើម្បីបង្កលក្ខណៈសម្បត្តិឱ្យពលករទទួលបានរបបគាំពារសង្គមទាំងក្នុងពេលធ្វើការ និងពេលដែលវិលត្រឡប់មកមាតុប្រទេសវិញ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- បេឡាជាតិសន្តិសុខសង្គម<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលបំណងទី៣៖ ការផ្សារភ្ជាប់ទេសន្តរប្រវេសន៍ការងារទៅនឹងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច** | | | | |
| គោលដៅ៣.១៖ លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការប្រើប្រាស់ | ១- ជំរុញទីភ្នាក់ងារជ្រើសរើសឯកជនជួយសម្របសម្រួលដល់ពលករទេសន្តរប្រវេសន៍ ក្នុងការបង្កើតគណនីធនាគារ ដើម្បីងាយស្រួលទទួលប្រាក់ឈ្នួល ឬប្រាក់អត្ថប្រយោជន៍ផ្សេងៗ និងផ្ញើប្រាក់តាមប្រព័ន្ធធនាគារនៅតាមប្រទេសគោលដៅ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| **ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍** | ២- លើកទឹកចិត្តគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការផ្តល់សេវាផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍ពីប្រទេសទទួលឱ្យកាន់តែទូលំទូលាយ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- ជំរុញពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសាររបស់ពួកគេក្នុងការប្រើប្រាស់ប្រព័ន្ធធនាគារ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤- សិក្សាអំពីការអនុវត្តការផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍ពីបណ្តាប្រទេសផ្សេងៗ ដើម្បីបង្កើនការយល់ដឹងអំពីសេវាផ្ញើប្រាក់ និងការចំណាយលើសេវាផ្ញើប្រាក់។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, អង្គការ UN Women, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងដៃគូពាក់ព័ន្ធ |
| **គោលដៅ៣.២៖ ពង្រឹងយន្តការគាំទ្រគ្រួសារពលករ និងយន្តការសមាហរណកម្មពលករទេសន្តរប្រវេសន៍ក្នុងសហគមន៍** | ១- សហការជាមួយទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ ក្នុងការធ្វើមាតុភូមិនិវត្តន៍របស់ពលករឱ្យមានសុវត្ថិភាព និងទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗស្របតាមការកំណត់ដោយច្បាប់របស់ប្រទេសទទួល។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ២- ផ្តល់សេវាគាំទ្រ និងប្រឹក្សាយោបល់ដល់ពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ អំពីវប្បធម៌ ការគ្រប់គ្រងអារម្មណ៍ផ្លូវកាយ និងផ្លូវចិត្ត ពាក់ព័ន្ធជាមួយនឹងទីតាំងភូមិសាស្ត្រស្រុកកំណើតរបស់ពលករមុនពេលធ្វើសមាហរណកម្មក្នុងគ្រួសារ និងសហគមន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, អង្គការ UN Women, ដៃគូអភិវឌ្ឍន៍, សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងដៃគូពាក់ព័ន្ធ |
| | ៣- សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ ទីភ្នាក់ងារជ្រើសរើសឯកជន និងសហគមន៍ពលករ ចងក្រងទិន្នន័យ និងចុះឈ្មោះពលករដែលចប់កិច្ចសន្យាការងារទៅក្នុងទិន្នន័យរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ឱកាសការងារ និងសេវារកការងារឱ្យធ្វើក្នុងស្រុក និងក្រៅស្រុក។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ទីភ្នាក់ងារជាតិមុខរបរ និងការងារ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៤- រៀបចំយន្តការផ្តល់សេវាគាំទ្រដល់គ្រួសាររបស់ពលករក្នុងការប្រាស្រ័យទាក់ទងជាមួយពលករ, សេវាទទួលប្រាក់បញ្ញើ និងលទ្ធភាពបង្កើតជាសហគមន៍គ្រួសារពលករដើម្បីចែករំលែកនូវព័ត៌មាន និងបទពិសោធន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ធនាគារជាតិនៃកម្ពុជា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៥- ផ្តល់ការបណ្តុះបណ្តាលចំណេះដឹងផ្នែកសហគ្រិនភាព និងហិរញ្ញវត្ថុ ជាពិសេសការប្រើប្រាស់ប្រាក់បញ្ញើឱ្យ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋា |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ទទួលបានផលប្រយោជន៍ខ្ពស់ និងសេវាប្រឹក្សាយោបល់ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងការប្រកបអាជីវកម្ម និងការវិនិយោគផ្សេងៗ។ | | - ក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | ភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| **គោលដៅ៣.៣៖ ពង្រីកទីផ្សារការងារដែលមានជំនាញ លើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មុនពេលចេញដំណើរ និងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍** | ១- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យមលើភាសា ជំនាញវិជ្ជាជីវៈ និងសុខភាពនិងសុវត្ថិភាពការងារ ដើម្បីបង្កើនសមត្ថភាពរបស់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ២- ពិគ្រោះយោបល់ជាមួយតំណាងរដ្ឋាភិបាល និងនិយោជកនៃប្រទេសទទួល អំពីតម្រូវការទីផ្សារការងារជំនាញវិជ្ជាជីវៈ និងវិស័យជាក់លាក់នីមួយៗ ជាពិសេសការទទួលស្គាល់ជំនាញ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល, សហជីព និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៣- បន្តសម្របសម្រួលជាមួយរដ្ឋសមាជិកអាស៊ានផ្សេងទៀតដើម្បីបង្កើតស្តង់ដារួមនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្នុងក្របខណ្ឌអាស៊ានសម្រាប់ពលករទេសន្តរប្រវេសន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | អង្គការ ILO, អង្គការ IOM, ដៃគូអភិវឌ្ឍន៍ និងសមាគមទីភ្នាក់ងារជ្រើសរើសឯកជន |

| គោលបំណង និង គោលដៅ | វិធានការ/ផែនការសកម្មភាព | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត | ភាគីពាក់ព័ន្ធដែលរួមចំណែកក្នុងការអនុវត្ត |
|---|---|---|---|---|
| | ៤- លើកកម្ពស់ការទទួលស្គាល់ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ជំនាញ និងគុណវុឌ្ឍិសម្រាប់ពលករទេសន្តរប្រវេសន៍ និងក្រុមជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះនៅប្រទេសគោលដៅ។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |
| | ៥- ជំរុញការទទួលស្គាល់ជំនាញដោយធ្វើការវាយតម្លៃជំនាញដែលបានទទួលការបណ្តុះបណ្តាលស្តង់ដាសមត្ថភាព និងការចេញវិញ្ញាបនបត្របញ្ជាក់ជំនាញដល់ពលករទេសន្តរប្រវេសន៍បន្ទាប់ពីពួកគេបានធ្វើមាតុភូមិនិវត្តន៍។ | ២០១៩-២០២៣ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ | សមាគមទីភ្នាក់ងារជ្រើសរើសឯកជន និងទីភ្នាក់ងារជ្រើសរើសឯកជន |

## ឧបសម្ព័ន្ធ៣ ៖ អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងទ្វេភាគី

| ល.រ | ប្រទេសទទួល | អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀង | កាលបរិច្ឆេទចុះហត្ថលេខា |
|---|---|---|---|
| ១ | ប្រទេសថៃ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ | ថ្ងៃទី៣០ខែតុលា ឆ្នាំ២០១៤ |
| | | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ | ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥ |
| | | កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្ម | ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៥ |
| ២ | សាធារណរដ្ឋកូរ៉េ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េតាមរយៈប្រព័ន្ធអនុញ្ញាតមុខរបរ(EPS) | ថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០៦ |
| ៣ | ប្រទេសជប៉ុន | អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការលើកម្មវិធីបណ្តុះបណ្តាលកម្មសិក្សាការីជំនាញបច្ចេកទេស | ថ្ងៃទី១១ខែកក្កដា ឆ្នាំ២០១៧ |
| ៤ | ប្រទេសម៉ាឡេស៊ី | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើស និងប្រើប្រាស់ពលករ | ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ |
| | | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើស និងការប្រើប្រាស់ពលករការងារផ្ទះ | ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ |
| ៥ | ប្រទេសសិង្ហបុរី | លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ១៤៩២ សជណ.អវ | ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ |
| ៦ | តំបន់រដ្ឋបាលពិសេសហុងកុង | សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ៤៣៣ សជណ.អវ | ថ្ងៃទី២៩ខែឧសភា ឆ្នាំ២០១៧ |
| ៧ | អារ៉ាប់ប៊ីសាអូឌីត | កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករ | ថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០១៦ |
| | | កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសពលករការងារផ្ទះ | ថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០១៦ |
| ៨ | រដ្ឋគូវ៉ែត | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីវិស័យផ្លាស់ប្តូរហត្ថពលកម្ម | ថ្ងៃទី១៣ខែមករា ឆ្នាំ២០០៩ |
| ៩ | រដ្ឋកាតា | កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងការប្រើប្រាស់ហត្ថពលកម្ម | ថ្ងៃទី៩ខែឧសភា ឆ្នាំ២០១១ |

| | | | |
|---|---|---|---|
| ១០ | **ប្រទេសវៀតណាម** | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ | ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ |
| ១១ | **ប្រទេសទីម័រឡេស្តេ** | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ | ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ |
| ១២ | **ប្រទេសហ្វីលីពីន** | អនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ |
| | | សេចក្តីថ្លែងការណ៍រួមស្តីពីការការពារជនទេសន្តរប្រវេសន៍ និងពលករទេសន្តរប្រវេសន៍ | ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៦ |
| ១៣ | **ប្រទេសបង់ក្លាដេស** | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ |

# ឧបសម្ព័ន្ធ៤ ៖ តួនាទី និងភារកិច្ចរបស់អនុព័ន្ធការងារ

តួនាទី និងភារកិច្ចរបស់អនុព័ន្ធការងារមានដូចខាងក្រោមៈ

**១. ការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករនៅក្នុងប្រទេសទទួល**

- ធានាថាពលករកម្ពុជាមិនត្រូវបានកេងប្រវ័ញ្ច រំលោភបំពាន ឬរើសអើងនៅកន្លែងការងារ
- ធានាភាពត្រឹមត្រូវ និងតម្លាភាពនៃលក្ខខណ្ឌ និងកិច្ចសន្យាការងារ
- ជួយដោះស្រាយបញ្ហាពលករដែលកើតមានឡើងក្នុងពេលបំពេញការងារដូចជាបញ្ហាបើកប្រាក់ឈ្នួល ការរំលោភកិច្ចសន្យាការងារជាដើម
- ផ្តល់ជំនួយផ្លូវច្បាប់ និងសុខុមាលភាព
- គាំទ្រ និងជួយពលករឱ្យមានឯកសារត្រឹមត្រូវ និងជួយដោះស្រាយបញ្ហារបស់ពលករដែលមិនមានឯកសារ
- សម្របសម្រួលការបញ្ជូនអដ្ឋិធាតុ ឬសព និងការទទួលបានជានារ៉ាប់រងនិងអត្ថប្រយោជន៍នានាស្របទៅតាមច្បាប់នៃប្រទេសទទួល ក្នុងករណីមានពលករទទួលមរណភាពជាយថាហេតុ។

**២. លើកកម្ពស់ការងារ និងស្វែងរកឱកាសការងារសម្រាប់ពលករ**

- ស្វែងរកឱកាសការងារផ្សេងៗសម្រាប់ជនជាតិខ្មែរនៅបរទេស
- វាយតម្លៃព័ត៌មានទីផ្សារការងារ
- ផ្សព្វផ្សាយដល់ពលករអំពីបទប្បញ្ញត្តិថ្មីៗទាក់ទងនឹងសិទ្ធិ និងផលប្រយោជន៍របស់ពួកគាត់។

**៣. ផ្តល់ធាតុចូលក្នុងការកសាងច្បាប់/គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា**

- ផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងពលកម្មនៅក្នុងប្រទេសទទួល
- ផ្តល់ជំនួយក្នុងការបង្កើតកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសទទួលដើម្បីការពារការងារ និងធានាលក្ខខណ្ឌការងារសមរម្យសម្រាប់ជនជាតិខ្មែរនៅបរទេស
- ធានាលើការលើកកម្ពស់យេនឌ័រក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ការងារ។

**៤. លើកកម្ពស់ទំនាក់ទំនងល្អនៅក្នុងប្រទេសទទួល**

- បង្កើតទំនាក់ទំនងល្អជាមួយសហគមន៍ពលករ និងសហគមន៍និយោជក
- បង្កើតទំនាក់ទំនងល្អជាមួយស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល ក្នុងការបំពេញភារកិច្ចរបស់ខ្លួន
- សម្របសម្រួលការងារជាមួយស្ថាប័នទទួលបន្ទុកវិស័យការងារ ដែលជាសមភាគីរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមបណ្តាប្រទេសទទួល
- បង្កើតទំនាក់ទំនងល្អជាមួយក្រុមអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសទទួល។

**គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣** ត្រូវបានរៀបចំ និងចងក្រង ក្រោមការណែនាំ និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** និងដោយៈ

| **ល.រ** | **គោត្តនាម-នាម** | **តួនាទី** |
|---|---|---|
| ១ | ឯកឧត្តម **ហ៊ី ឌុឡារី** | អនុរដ្ឋលេខាធិការ |
| ២ | ឯកឧត្តម **សេង សក្តា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ |
| ៣ | លោក **ជួប ណារ៉ាត់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ |
| ៤ | លោក **ឆាង ស៊ាងវេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ |
| ៥ | លោក **ឡៅ ទិត្យាកោមល** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៦ | លោក **ហួន សុខភានាថ** | អនុប្រធាននាយកដ្ឋានអធិការកិច្ច |
| ៧ | លោក **ភុន សុភ័ក្រ្ត** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៨ | លោក **ថូ ប៊ុនថន** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ៩ | លោក **អ៊ុក វ៉ាឌុច** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១០ | លោក **គន់ សម្បត្តិ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១១ | លោក **ទូច ពណ្ណារាយ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១២ | លោក **ឃីម សុសំរេច** | ប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៣ | លោកស្រី **ហួង សុភ័ក្រ** | ប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៤ | លោក **គយចៅ វិសាល** | ប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៥ | លោក **ហ៊ី ចាន់ណារ៉ា** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៦ | លោក **ជួង ដារិទ្ធ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ១៧ | លោក **វ៉ាន់ វិត** | អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃអង្គការ ILO |
| ១៨ | លោកជំទាវឧកញ៉ា **អ៊ឹង ស៊ាងរិទ្ធី** | ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា |
| ១៩ | លោក **អន ប៊ុនហាក់** | ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា |
| ២០ | លោក **នាក់ ហេង** | ប្រធានសមាគមដឹកជញ្ជូន និងការងារក្រៅប្រព័ន្ធ ស.ជ.ក.ប |
| ២១ | កញ្ញា **ឈឿន មាលតី** | មន្ត្រី នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២២ | កញ្ញា **សេង និតា** | មន្ត្រី នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២៣ | លោក **ឈាង សារៈបញ្ញា** | មន្ត្រី នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២៤ | ថ្នាក់ដឹកនាំ និងមន្ត្រី | គ្រប់អង្គភាពដែលបានសហការផ្តល់នូវស្ថិតិ និងរបាយការណ៍នានា |

# គោលនយោបាយ
# ស្តីពី
# ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា
# ឆ្នាំ២០១៩-២០២៣

## ចក្ខុវិស័យនៃគោលនយោបាយ

ដើម្បីពង្រឹងយន្តការគ្រប់គ្រង ការពារ និងលើកកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ប្រកបដោយប្រសិទ្ធភាព សំដៅធានាការទទួលបានឱកាសការងារសមរម្យ ការអភិវឌ្ឍជំនាញចំណេះដឹង បទពិសោធន៍ធនធាន និងអត្ថប្រយោជន៍នៃកិច្ចគាំពារសង្គមដល់ពលករ សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច

### គោលបំណងទី១
ការពង្រឹង
អភិបាលកិច្ច
ទេសន្តរប្រវេសន៍
ការងារ

### គោលបំណងទី២
ការការពារនិង
លើកកម្ពស់សិទ្ធិ
ពលករទេសន្តរ
ប្រវេសន៍

### គោលបំណងទី៣
ការផ្សារភ្ជាប់
ទេសន្តរប្រវេសន៍
ការងារទៅនឹងការ
អភិវឌ្ឍសង្គម
និងសេដ្ឋកិច្ច

## គោលដៅ

១. ធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ

២. ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីនិងថ្នាក់តំបន់លើទេសន្តរប្រវេសន៍ការងារ

៣. ពង្រឹងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

៤. បន្តកសាងសមត្ថភាពមន្ត្រី និងទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារ និងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៥. ប្រមូល ចងក្រង និងវិភាគទិន្នន័យពាក់ព័ន្ធ នឹងពលករទេសន្តរប្រវេសន៍

៦. បង្កើតមណ្ឌលធនធានពលករទេសន្តរប្រវេសន៍(Migrant Resources Center - MRC) ក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## គោលដៅ

១. ពង្រឹង និងពង្រីកសេវាទីប្រឹក្សាទទួលបន្ទុកពលករ/អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ ស្ថានអគ្គកុងស៊ុល/ ស្ថានកុងស៊ុល នៅបណ្តាប្រទេសទទួល

២. ពង្រឹងយន្តការទទួល និងដោះស្រាយបណ្តឹងពលករទេសន្តរប្រវេសន៍

៣. ចងក្រង ផលិត បោះពុម្ពឯកសារ និងផ្សព្វផ្សាយអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពឱ្យបានទូលំទូលាយ

៤. ពង្រឹង និងពង្រីកយន្តការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីកិច្ចគាំពារសង្គមដល់ពលករទេសន្តរប្រវេសន៍

## គោលដៅ

១. លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រព័ន្ធធនាគារដល់ពលករទេសន្តរប្រវេសន៍

២. ពង្រឹងយន្តការគាំទ្រគ្រួសារពលករ និងយន្តការសមាហរណកម្មពលករទេសន្តរប្រវេសន៍ក្នុងសហគមន៍

៣. ពង្រីកទីផ្សារការងារដែលមានជំនាញលើកកម្ពស់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មុនពេលចេញដំណើរនិងការទទួលស្គាល់ជំនាញរបស់ពលករទេសន្តរប្រវេសន៍